អេស៊ីលីដា
ACLEDA BANK

# របាយការណ៍ប្រចាំត្រីមាសទី៤

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

## ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ (គិតជាលានរៀល) | ត្រីមាសទី៤ ឆ្នាំ២០២៥ | ឆ្នាំ២០២៤ | ឆ្នាំ២០២៣ |
|---|---|---|---|
| ទ្រព្យសកម្មសរុប | ៤៨.២២៥.៣៣៤ | ៤៣.៦០៦.១៧៣ | ៣៩.៨០៤.៤០៥ |
| បំណុលសរុប | ៤១.៥៤៨.៧៤៤ | ៣៧.៦០៨.២៥១ | ៣៤.១៥៨.៨៥០ |
| មូលធនសរុប | ៦.៦៧៦.៥៨៩ | ៥.៩៩៧.៩២២ | ៥.៦៤៥.៥៥៥ |
| **លទ្ធផលហិរញ្ញវត្ថុ (គិតជាលានរៀល)** | **ត្រីមាសទី៤ ឆ្នាំ២០២៥** | **ត្រីមាសទី៤ ឆ្នាំ២០២៤** | **ត្រីមាសទី៤ ឆ្នាំ២០២៣** |
| ចំណូលសរុប | ៩៩៦.២១៦ | ៨៩៧.០៧១ | ៨៧៤.១០២ |
| ចំណេញ/(ខាត) មុនបង់ពន្ធ | ២៥០.១៧៥ | ២៤៨.២១៩ | ១៨៦.១០៧ |
| ចំណេញ/(ខាត) សុទ្ធក្នុងការិយបរិច្ឆេទ | ២០១.១៩៧ | ១៩២.៦៩២ | ១៥០.៦១២ |
| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ | ១៩៥.៦៤២ | ១៦៦.៤៦០ | ៩១.៥០៩ |
| **អនុបាតហិរញ្ញវត្ថុ (%)** | **ត្រីមាសទី៤ ឆ្នាំ២០២៥** | **ឆ្នាំ២០២៤** | **ឆ្នាំ២០២៣** |
| អនុបាតសាធនភាព | ២០,១៧% | ១៨,៦៤% | ១៨,៤៥% |
| អនុបាតបំណុលធៀបនឹងមូលធន | ៦២២,៣០% | ៦២៧,០២% | ៦០៥,០៦% |
| អនុបាតក្របខ័ណ្ឌសន្ទនីយភាព | ៤១៤,០៥% | ២៥០,៧៦% | ១៨០,១៣% |
| អនុបាតឥណទានមិនដំណើរការ (*) | ៥,៩៤% | ៥,៤៧% | ៥,៧៧% |
| អនុបាតឥណទានធៀបនឹងប្រាក់បញ្ញើ | ៨១,៤៨% | ៨៥,១៧% | ៩២,១១% |
| តម្លៃចុះបញ្ជីក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល) | ១៥.៣៥៥ | ១៣.៧៩០ | ១២.៩៧៧ |
| | **ត្រីមាសទី៤ ឆ្នាំ២០២៥** | **ត្រីមាសទី៤ ឆ្នាំ២០២៤** | **ត្រីមាសទី៤ ឆ្នាំ២០២៣** |
| អនុបាតចំណេញធៀបនឹងទ្រព្យសកម្មមធ្យម (ROAA)(**) | ០,៤២% | ០,៤៥% | ០,៣៨% |
| អនុបាតចំណេញធៀបនឹងមូលធនមធ្យម (ROAE)(**) | ៣,០៦% | ៣,២៧% | ២,៧០% |
| អនុបាតលទ្ធភាពបង់ការប្រាក់ (ដង) | ១,៨១ | ១,៧៣ | ១,៥២ |
| ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល) | ៤៦៣,៥៨ | ៤៤៤,២០ | ៣៤៧,៤៩ |
| ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | គ្មាន | គ្មាន | គ្មាន |
| អនុបាតហិរញ្ញវត្ថុសំខាន់ៗផ្សេងទៀត | គ្មាន | គ្មាន | គ្មាន |

(*) អនុបាតឥណទានមិនដំណើរការ = សមតុល្យប្រាក់ដើមតាមកិច្ចសន្យារបស់ឥណទានមិនដំណើរការ / សមតុល្យប្រាក់ដើមឥណទានតាមកិច្ចសន្យាសរុប

(**) . អនុបាតទាំងនេះមិនមែនជាអនុបាតប្រចាំឆ្នាំនោះទេ ហើយត្រូវបានគណនាដោយប្រើតួលេខប្រាក់ចំណេញដែលផ្តល់ជូនដល់ភាគហ៊ុនិករបស់ធនាគាររយៈពេល ៣ខែ ចាប់ពីថ្ងៃទី១ ខែតុលា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥។

. អនុបាតចំណេញធៀបនឹងទ្រព្យសកម្មមធ្យម = ប្រាក់ចំណេញក្នុងការិយបរិច្ឆេទដែលផ្តល់ជូនដល់ភាគហ៊ុនិករបស់ធនាគារ / ទ្រព្យសកម្មសរុបមធ្យម

. អនុបាតចំណេញធៀបនឹងមូលធនមធ្យម = ប្រាក់ចំណេញក្នុងការិយបរិច្ឆេទដែលផ្តល់ជូនដល់ភាគហ៊ុនិករបស់ធនាគារ / មូលធនមធ្យមផ្តល់ជូនភាគហ៊ុនិករបស់ធនាគារ

# ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប






# អនុបាតហិរញ្ញវត្ថុ (%)







ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល)
៣៤៧,៤៩
៤៤៤,២០
៤៦៣,៥៨
ត្រីមាសទី៤ ឆ្នាំ២០២៣
ត្រីមាសទី៤ ឆ្នាំ២០២៤
ត្រីមាសទី៤ ឆ្នាំ២០២៥


តម្លៃចុះបញ្ជីក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល)
១២.៩៧៧
១៣.៧៩០
១៥.៣៥៥
ឆ្នាំ២០២៣
ឆ្នាំ២០២៤
ត្រីមាសទី៤ ឆ្នាំ២០២៥

# សមាសភាពក្រុមប្រឹក្សាភិបាល



**លោកស្រី គីម សុធារី**
*ប្រធានក្រុមប្រឹក្សាភិបាល*



**បណ្ឌិត អ៊ិន ចាន់នី**
*អភិបាលប្រតិបត្តិ*



**បណ្ឌិត Albertus Bruggink**
*អភិបាលមិនប្រតិបត្តិ*



**លោក Kaoru Furuya**
*អភិបាលមិនប្រតិបត្តិ*



**លោក Olivier Louis Roger Fouchet**
*អភិបាលមិនប្រតិបត្តិ*



**លោក Pieter Kooi**
*អភិបាលឯករាជ្យ*



**លោកស្រី ភូរិ រតនា**
*អភិបាលឯករាជ្យ*



**លោក កាយ ឡូត**
*អភិបាលឯករាជ្យ*



**បណ្ឌិត ហេង ឌីណា**
*អភិបាលឯករាជ្យ*

# សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល

តាងនាមឱ្យធនាគារ អេស៊ីលីដា ភីអិលស៊ី (“ធនាគារ អេស៊ីលីដា”) និងក្រុមប្រឹក្សាភិបាល នាងខ្ញុំមានកិត្តិយស និងសេចក្តីសោមនស្សរីករាយ សូមផ្តល់ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាសទី៤ ឆ្នាំ២០២៥ របស់ធនាគារ អេស៊ីលីដា និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ធនាគារ (“សម្ព័ន្ធធនាគារ”) គិតចាប់ពីថ្ងៃទី១ ខែតុលា ឆ្នាំ២០២៥ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ដល់ភាគីពាក់ព័ន្ធទាំងអស់។

នៅត្រីមាសទី៤ ឆ្នាំ២០២៥ កំណើនសេដ្ឋកិច្ចពិភពលោកបន្តមានកម្រិតមធ្យម និងភាពមិនប្រាកដប្រជា ដោយសារការសម្រាលអតិផរណា និងភាពធន់នឹងតម្រូវការប្រើប្រាស់ប៉ុន្តែក៏ត្រូវបានរារាំងដោយភាពតានតឹងភូមិសាស្ត្រនយោបាយកើនឡើង ការកើនឡើងនៃបំណុល ភាពមិនប្រាកដប្រជានៅក្នុងលក្ខខណ្ឌពាណិជ្ជកម្ម និងហិរញ្ញវត្ថុ ព្រមទាំងការប្រឈមផ្នែកគោលនយោបាយរូបិយវត្ថុ និងសារពើពន្ធនៅទូទាំងតំបន់ជាច្រើន។ សេដ្ឋកិច្ចអាមេរិកបានកើនឡើង ៤,៣% ក្នុងត្រីមាសទី៣ កើនឡើងពី ៣,៨% ក្នុងត្រីមាសទី២ ដោយសារការចំណាយរបស់អ្នកប្រើប្រាស់ ការនាំចេញកើនឡើង ការចំណាយរបស់រដ្ឋាភិបាលកើនឡើង និងការនាំចូលថយចុះ (U.S. Bureau of Economic Analysis, 2025)។ ធនាគារកណ្តាលអាមេរិកនៃរដ្ឋ Atlanta សហរដ្ឋអាមេរិក ព្យាករថាកំណើនផលិតផលក្នុងស្រុកសរុបរបស់អាមេរិកនឹងកើនឡើងដល់ ៥,៣% ក្នុងត្រីមាសទី៤ ឆ្នាំ២០២៥ ដែលគាំទ្រចម្បងដោយការចំណាយរបស់អ្នកប្រើប្រាស់ដែលមានភាពធន់ ទីផ្សារការងាររឹងមាំ ការបន្ធូរបន្ថយអតិផរណា និងលក្ខខណ្ឌហិរញ្ញវត្ថុដ៏ល្អប្រសើរ។ សេដ្ឋកិច្ចចិនបានកើនឡើង ៤,៤% ក្នុងត្រីមាសទី៤ ឆ្នាំ២០២៥ ធ្លាក់ចុះពី ៤,៨% ក្នុងត្រីមាសទី៣ ដោយសារទិន្នផលផលិតកម្មកាន់តែខ្លាំង ការបន្តការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ ការពង្រឹងការនាំចេញ និងការជំរុញរបស់រដ្ឋាភិបាលដែលមានគោលដៅដើម្បីពង្រឹងតម្រូវការក្នុងស្រុក ខណៈដែលប្រឈមមុខនឹងការចំណាយក្នុងស្រុកថយចុះ ស្របពេលមានវិស័យអចលនទ្រព្យមានកំណើនយឺត និងសម្ពាធអតិផរណា (National Bureau of Statistics of China, 2025)។ ផលិតផលក្នុងស្រុកសរុបនៃតំបន់អឺរ៉ូត្រូវបានគេព្យាករថានឹងថយចុះក្នុងត្រីមាសទី៤ ឆ្នាំ២០២៥ បន្ទាប់ពីបានកើនឡើងចំនួន ០,៣% ក្នុងត្រីមាសទី៣ ឆ្នាំ២០២៥ ដែលជំរុញដោយការបន្ធូរបន្ថយអតិផរណា ការងើបឡើងវិញបន្តិចម្តងៗនៃការប្រើប្រាស់ ការពង្រឹងលក្ខខណ្ឌចាមពល និងសកម្មភាពសេវាកម្មដែលមានភាពធន់ ទោះបីជាទិន្នផលឧស្សាហកម្មនៅតែមានកំណើនបន្តិចបន្តួចក៏ដោយ (Eurostat, 2025)។ សេដ្ឋកិច្ចជប៉ុនត្រូវបានគេព្យាករថានឹងត្រឡប់មករកស្ថានភាពល្អប្រសើរវិញនៅត្រីមាសទី៤ ឆ្នាំ២០២៥ បន្ទាប់ពីមានកំណើនចំនួន ២,៣% ក្នុងត្រីមាសទី៣ ដោយសារការងើបឡើងវិញនៃការវិនិយោគលំនៅឋាន និងការកើនឡើងនៃការចំណាយមូលធន ខណៈពេលមានការនាំចេញទាប (Japan Centre for Economic Research, 2025)។ ទន្ទឹមនឹងនេះ សេដ្ឋកិច្ចអាស៊ានបានបន្តការរីកចម្រើនក្នុងកម្រិតមធ្យម ដែលគាំទ្រដោយតម្រូវការក្នុងស្រុកយ៉ាងល្អប្រសើរ កំណើននៃការនាំចេញ និងការវិនិយោគសាធារណៈ ទោះបីជាមានផលប៉ះពាល់ពីភាពតានតឹងនៃពាណិជ្ជកម្មពិភពលោក និងតម្រូវការមួយចំនួនពីដៃគូសំខាន់ៗបានបន្ថយការរំពឹងទុកនៃកំណើនក៏ដោយ។

ក្នុងបរិបទនេះ សេដ្ឋកិច្ចកម្ពុជាបានបន្តមានកំណើនក្នុងកម្រិតមធ្យមក្នុងត្រីមាសទី៤ ឆ្នាំ២០២៥ ក្នុងស្ថានភាពនៃភាពមិនប្រាកដប្រជាជាសាកលកាន់តែខ្លាំង ភាពតានតឹង និងការបិទព្រំដែនកម្ពុជា-ថៃ ដែលបានរំខានដល់ពាណិជ្ជកម្មឆ្លងដែន ចំណូលពីវិស័យទេសចរណ៍មានកំណើនយឺតជាងមុន និងលំហូរប្រាក់ផ្ញើពីក្រៅប្រទេសមានកម្រិតទាបជាងមុន។ សកម្មភាពពាណិជ្ជកម្មមានភាពធន់ ដែលគាំទ្រដោយកំណើនការនាំចេញ វាយនភណ្ឌ ស្បែកជើង ទំនិញធ្វើដំណើរ ការបន្តពង្រីកផលិតកម្មមិនមែនកាត់ដេរ និងលំហូរវិនិយោគឯកជនមានស្ថិរភាព។ កំណើននេះក៏ទទួលបានការជំរុញដោយគោលនយោបាយរបស់រដ្ឋាភិបាល រួមទាំងការបន្តការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ការលើកទឹកចិត្តផ្នែកពន្ធ និងវិធានការសម្រួលពាណិជ្ជកម្មសម្រាប់ឧស្សាហកម្មដែលផ្តោតលើការនាំចេញ កម្មវិធីគាំទ្រសម្រាប់សហគ្រាសធុនតូច និងមធ្យម (SMEs) និងវិធានការសារពើពន្ធដែលមានគោលដៅ ដើម្បីជំរុញតម្រូវការក្នុងស្រុក និងរក្សាទំនុកចិត្តរបស់វិនិយោគិន។ ទន្ទឹមនឹងនេះ វិស័យធនាគារនៅកម្ពុជាបន្តមានមូលដ្ឋានដ៏មានស្ថិរភាព ដែលទទួលបានការគាំទ្រដោយសាច់ប្រាក់ងាយស្រួលគ្រប់គ្រាន់ និងទ្រនាប់ដើមទុនរឹងមាំ ទោះបីជាបានប្រឈមនឹងផលប៉ះពាល់ដែលកំពុងកើតមានពីកំណើនឥណទានយឺតជាងមុន និងកម្រិតខ្ពស់នៃប្រាក់កម្ចីមិនដំណើរការ (NBC Annual Report 2025) ក៏ដោយ។

ធនាគារ អេស៊ីលីដា បាននិងកំពុងបន្តធ្វើឱ្យប្រសើរឡើងនូវមុខងារស្វ័យប្រតិបត្តិការជាច្រើននៅលើ**អេស៊ីស្ទ័រអេប** យូអរក្លូម៉ាស៊ីនអេធីអឹម និងម៉ាស៊ីនឆូតកាត ស្របតាមតម្រូវការរបស់អតិថិជន និងវិវឌ្ឍនាការបច្ចេកវិទ្យាឌីជីថល។ ទន្ទឹមនឹងនេះ ដើម្បីបំពេញតម្រូវការរបស់អតិថិជនឱ្យកាន់តែប្រសើរឡើង ធនាគារ អេស៊ីលីដា បានបន្ថែមម៉ោងបម្រើអតិថិជន រហូតដល់ម៉ោង ៧:០០យប់ នៅតាមសាខាមួយចំនួនទាំងនៅក្នុងរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត។ ទន្ទឹមនឹងនេះ សម្ព័ន្ធធនាគារ អេស៊ីលីដា បានពង្រីកសេវាកម្ម

ធនាគារស្វ័យប្រវត្តិចំនួន **២២២ទីតាំង (៦៥ទីតាំង នៅរាជធានីភ្នំពេញ និង១៥៧ទីតាំង នៅតាមបណ្តាខេត្ត)** បន្ថែមលើ **៣២១ ការិយាល័យ** ព្រមទាំងបានបំពាក់ម៉ាស៊ីនអេធីអឹមចំនួន **១.៦៥១គ្រឿង** ម៉ាស៊ីនឆូតកាតចំនួន **៦.៥០៦គ្រឿង** និងឃ្យូអរកូដតាមសំណើសុំរបស់អតិថិជន សម្រាប់គាំទ្រប្រតិបត្តិការផ្ទេរប្រាក់ និងទូទាត់នៅតាមបញ្ជរស្ថាប័នឯកជន ដែលមាន ផ្សារ ហាងទំនិញ សណ្ឋាគារ ភោជនីយដ្ឋាន គ្រឹះស្ថានសិក្សា មន្ទីរពេទ្យ ទីភ្នាក់ងារទេសចរណ៍ ស្ថានីយប្រេងឥន្ធនៈ និងអាជីវកម្មនានា នៅទូទាំងប្រទេស និងការទូទាត់ឆ្លងប្រទេស (QR Cross Board Payment) ជាបន្តបន្ទាប់។ គិតត្រឹមដំណាច់ត្រីមាសទី៤ ឆ្នាំ២០២៥នេះ សម្ព័ន្ធធនាគារ អេស៊ីលីដា មានអ្នកប្រើប្រាស់ **អេស៊ីស្ទូតើអេប** ចំនួនច្រើនជាង **៥,៦៤ លាននាក់** ជាពិសេសក្នុងនោះ មានដៃគូអាជីវកម្មសរុប **០,៨០ លាននាក់**។ បន្ថែមលើនេះ ធនាគារ អេស៊ីលីដា បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាជាច្រើនជាមួយនឹងស្ថាប័នរដ្ឋ និងឯកជនជាបន្តបន្ទាប់ ក្នុងការពង្រីកវិសាលភាព និងការផ្តល់ភាពងាយស្រួលក្នុងការទូទាត់ថ្លៃទំនិញ និងសេវាកម្មផ្សេងៗក្នុងតំបន់ និងក្រៅប្រទេស។

គិតត្រឹមដំណាច់ត្រីមាសទី៤ ឆ្នាំ២០២៥នេះ ទ្រព្យសកម្មសរុបរបស់សម្ព័ន្ធធនាគារ អេស៊ីលីដា បានកើនឡើងចំនួន **១.១៨៣,៤៥ លានដុល្លារអាមេរិក** ឬ **១០,៩២%** និងទ្រព្យសកម្មឥណទានសរុបបានកើនឡើងចំនួន **៥១៥,៤៣ លានដុល្លារអាមេរិក** ឬ **៧,២៤%** ធៀបនឹងដំណាច់ឆ្នាំ២០២៤។ បន្ថែមពីនេះ ប្រាក់បញ្ញើសរុបរបស់សម្ព័ន្ធធនាគារ អេស៊ីលីដា បានកើនឡើងចំនួន **១.០១០,២១** លានដុល្លារអាមេរិក ឬ **១២,០៩%** រហូតដល់ចំនួន **៩,៣៧** ប៊ីលានដុល្លារអាមេរិក ធៀបនឹងដំណាច់ឆ្នាំ២០២៤។

សម្ព័ន្ធធនាគារ (សម្រាប់ខែតុលា វិច្ឆិកា និងធ្នូ ឆ្នាំ២០២៥) ទទួលបានប្រាក់ចំណេញសរុបចំនួន **៥០,០៣ លានដុល្លារអាមេរិក** ខណៈដែលអនុបាតចំណេញធៀបនឹងទ្រព្យសកម្មមធ្យមមានចំនួន **០,៤២%** និងអនុបាតចំណេញធៀបនឹងមូលធនមធ្យមមានចំនួន **៣,០៦%**។

ជាទីបញ្ចប់ នាងខ្ញុំសូមថ្លែងអំណរគុណ និងសំដែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅ ចំពោះភាគីពាក់ព័ន្ធទាំងអស់ដែលបានបន្តផ្តល់ការជ្រោមជ្រែង និងការគាំទ្រដល់ធនាគារ។

ថ្ងៃអង្គារ ៨រោច ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២៦
ហត្ថលេខា និងត្រា

ធនាគារ អេស៊ីលីដា ភីអិលស៊ី
ACLEDA BANK PLC.

**គឹម សុធារី**

# មាតិកា


ព័ត៌មានហិរញ្ញវត្ថុសង្ខេប ..... i

ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប ..... ii

សមាសភាពក្រុមប្រឹក្សាភិបាល ..... v

សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល ..... vi

ផ្នែកទី១- ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីលក់មូលបត្រ ..... ១

ក- អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ ..... ១

ខ- លក្ខណៈនៃធុរកិច្ច ..... ១

គ- ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ..... ១

ផ្នែកទី២- ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច ..... ៣

ក- លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក ..... ៣

ខ- រចនាសម្ព័ន្ធចំណូល ..... ៦

ផ្នែកទី៣- របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មដោយសវនកររងករាជ្យ ..... ៦

ផ្នែកទី៤- ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង ..... ៧

ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ ..... ៧

ខ- កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ ..... ១០

គ- ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល ..... ១១

ឃ- ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ ..... ១១

ង- ផលប៉ះពាល់នៃអតិផរណា ..... ១២

ច- គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រាជរដ្ឋាភិបាល ..... ១២

ហត្ថលេខាអភិបាលរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ..... ១៥

# ផ្នែកទី១- ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីលក់មូលបត្រ

## ក- អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ

| | |
|---|---|
| ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ | **ធនាគារ អេស៊ីលីដា ភីអិលស៊ី** |
| ជាអក្សរឡាតាំង | **ACLEDA BANK PLC.** |
| លេខកូដស្តង់ដារ | KH១០០០១០០០០៣ |
| ទីស្នាក់ការ | អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |
| លេខទូរស័ព្ទ | +៨៥៥ (០)២៣ ៩៩៨ ៧៧៧ |
| គេហទំព័រ | www.acledabank.com.kh |
| អ៊ីម៉ែល | acledabank@acledabank.com.kh |
| លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម | ០០០០៣០៧៧ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០០០ ចេញដោយក្រសួងពាណិជ្ជកម្ម |
| លេខអាជ្ញាបណ្ណអាជីវកម្ម | ធ.ព.០៦ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២៣ ចេញដោយ ធនាគារជាតិ នៃ កម្ពុជា |
| សេចក្តីសម្រេចអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន | លេខ០៥៣/២០គ.ម.ក./ស.ស.រ. ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០ ចេញដោយនិយ័តករមូលបត្រកម្ពុជា “ន.ម.ក.” (ពីមុនជា គណៈកម្មការមូលបត្រកម្ពុជា “គ.ម.ក.”) |
| ឈ្មោះបុគ្គលតំណាងបុគ្គលចុះបញ្ជីលក់មូលបត្រ | **បណ្ឌិត អ៊ិន ចាន់នី** |

## ខ- លក្ខណៈនៃធុរកិច្ច

ធនាគារ អេស៊ីលីដា គឺជាធនាគារពាណិជ្ជដែលមានសាខា និងបណ្តាញការិយាល័យធំជាងគេបង្អស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ធនាគារ អេស៊ីលីដា ជាធនាគារពាណិជ្ជទី១ ដែលបានចុះបញ្ជីនៅក្នុងផ្សារមូលបត្រកម្ពុជា (ផមក) នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០។ បច្ចុប្បន្ននេះ ធនាគារ អេស៊ីលីដា មានក្រុមហ៊ុនបុត្រសម្ព័ន្ធចំនួន៤ រួមមាន៖ (១) ធនាគារ អេស៊ីលីដា ឡាវ លីមីតធីត (២) ស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា (៣) ក្រុមហ៊ុនមូលបត្រ អេស៊ីលីដា ម.ក និង (៤) សាកលវិទ្យាល័យ ពាណិជ្ជសាស្ត្រ អេស៊ីលីដា ឯ.ក ព្រមទាំងមានការិយាល័យតំណាង១នៅប្រទេសមីយ៉ាន់ម៉ា។

## គ- ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ

- នៅថ្ងៃទី៧ ខែតុលា ឆ្នាំ២០២៥ ធនាគារ អេស៊ីលីដា មានមោទនភាពយ៉ាងខ្លាំងដែលបានទទួលវិញ្ញាបនបត្រកម្រិតមាស (Gold Level Certification) ពីស្ថាប័ន MFR Global Rating Agency ក្នុងការការពារសុវត្ថិភាព និងទិន្នន័យអតិថិជន។ សមិទ្ធផលដ៏ល្អឥតខ្ចោះនេះ បញ្ជាក់ថាធនាគារ អេស៊ីលីដា មានសុចរិតភាព និងទំនួលខុសត្រូវខ្ពស់បំផុតអនុវត្តបាន ១០០% តាមស្តង់ដារសកលស្តីពីការគ្រប់គ្រង និងការពារសុវត្ថិភាពអតិថិជនជាចម្បង។
- នៅថ្ងៃទី៨ ខែតុលា ឆ្នាំ២០២៥ ធនាគារ អេស៊ីលីដា និងផ្សារមូលបត្រកម្ពុជា បានសហការគ្នារៀបចំ **"ពិធីចុះបញ្ជីលក់សញ្ញាបណ្ណបន្ទាប់បន្សំជាផ្លូវការរបស់ធនាគារ អេស៊ីលីដា"** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប** រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាភិបាលនៃផ្សារមូលបត្រកម្ពុជា ព្រមទាំងមានការចូលរួមពីអាជ្ញាធរពាក់ព័ន្ធ។ ការបោះផ្សាយសញ្ញាបណ្ណបន្ទាប់បន្សំនេះ ជាការចូលរួមចំណែកដ៏សំខាន់

ក្នុងការជំរុញកំណើន និងការអភិវឌ្ឍទីផ្សារមូលធននៅកម្ពុជា និងជាយន្តការថ្មី សម្រាប់ការកៀរគរប្រភពទុនក្នុងស្រុក សម្រាប់គាំទ្រអតិថិជន និងចូលរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងសង្គម។

- នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៥ ធនាគារ អេស៊ីលីដា បានទទួលពានរង្វាន់ "ប្រតិបត្តិករបរធនបាលឆ្នើម សម្រាប់ប្រតិបត្តិការបរធនបាលកិច្ច សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកសម្រាប់ទិញ-លក់អចលនវត្ថុ ប្រចាំឆ្នាំ២០២៤"។
- នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៥ ធនាគារ អេស៊ីលីដា បានទទួលពានរង្វាន់ "ប្រតិបត្តិករបរធនបាលឆ្នើម ដែលសកម្មក្នុងការងារសង្គម និងបរិស្ថាន ប្រចាំឆ្នាំ២០២៤"។
- នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៥ ធនាគារ អេស៊ីលីដា និងសមាគមជប៉ុន-កម្ពុជា បានសហការរៀបចំកម្មវិធីជំនួបធុរកិច្ចលើកទី៤ ដែលប្រព្រឹត្តឡើងនៅការិយាល័យកណ្តាល ធនាគារ អេស៊ីលីដា។ ព្រឹត្តិការណ៍នេះរៀបចំឡើងដោយជោគជ័យនូវព្រឹត្តិការណ៍នាឆ្នាំកន្លងមករួមមានក្នុងឆ្នាំ២០១៩ ២០២២ និង២០២៣ ដោយបានទាក់ទាញក្រុមហ៊ុនចំនួន ៦០ មកពីវិស័យចម្រុះរួមមានសហគ្រាសធុនតូច និងមធ្យម ផលិតកម្ម កសិកម្ម អចលនទ្រព្យ សំណង់ គ្រឿងសម្អាង ប្រព័ន្ធព័ត៌មានវិទ្យា និងបញ្ញាសិប្បនិម្មិត ការរចនាស្ថាបត្យកម្ម និងការប្រឹក្សាយោបល់។ កម្មវិធីជំនួបធុរកិច្ចលើកទី៤ ជាវេទិកាសម្រាប់ផ្លាស់ប្តូរចំណេះដឹងលើការគ្រប់គ្រងហិរញ្ញវត្ថុ ជំនាញបច្ចេកទេស និងនវានុវត្តន៍ដែលចាំបាច់សម្រាប់ភាពជោគជ័យក្នុងធុរកិច្ច។ ហើយកម្មវិធីនេះទៀតសោតក៏បើកឱកាសដល់វិនិយោគិនកម្ពុជា និងវិនិយោគិនជប៉ុន ដើម្បីធ្វើការណែនាំពីកិច្ចការវិនិយោគរវាងគ្នាទៅវិញទៅមកផងដែរ។
- នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៥ ធនាគារ អេស៊ីលីដា បានប្រកាសដាក់ឱ្យដំណើរការជាផ្លូវការដំណាក់កាលទី១ នៃការទូទាត់ឆ្លងដែនតាមយន្តអររកូដឆ្លងដែនរវាងប្រទេសកម្ពុជា និងសិង្ហបុរី **"កម្ពុជាស្កេនសិង្ហបុរី"**។ កិច្ចសហប្រតិបត្តិការនេះរៀបចំឡើងក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **លោកជំទាវ បណ្ឌិត ជា សិរី** អគ្គទេសាភិបាលធនាគារជាតិ នៃ កម្ពុជា។ ជាមួយនឹងការដាក់ឱ្យដំណើរការដំណាក់កាលទី១ ក្រោមកិច្ចសហការរវាងស្ថាប័នហិរញ្ញវត្ថុឈានមុខគេគឺធនាគារ អេស៊ីលីដា មកពីប្រទេសកម្ពុជា និងក្រុមហ៊ុន Liquid Group Pte. Ltd មកពីប្រទេសសិង្ហបុរី។ ប្រជាជនកម្ពុជាធ្វើដំណើរទៅប្រទេសសិង្ហបុរី អាចប្រើប្រាស់ប្រាក់រៀល តាមរយៈកម្មវិធី **អេស៊ីលីដាស៊ូភើអេប** ស្កេនទូទាត់លើ RoamQR ដែលមាននៅតាមអាជីវករ SGQR ទូទាំងប្រទេសសិង្ហបុរី បានភ្លាមៗ ងាយស្រួល រហ័ស និងមានសុវត្ថិភាព។ ក្រោមកិច្ចផ្តួចផ្តើមទ្វេភាគីនេះ បានលើកកម្ពស់ការប្រើប្រាស់រូបិយប័ណ្ណក្នុងស្រុក និងការទូទាត់ដោយប្រើប្រាស់ប័ណ្ណ។ នេះជាជំហានដ៏មានសារៈសំខាន់មួយទៀត ក្នុងការលើកកម្ពស់ពាណិជ្ជកម្ម ការវិនិយោគ និងជំរុញដល់ទេសចរណ៍រវាងប្រទេសទាំងពីរ ប្រកបដោយចីរភាព។
- នៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៥ ធនាគារ អេស៊ីលីដា មានមោទនភាពដែលបានទទួលពានរង្វាន់ ដៃគូប្រតិបត្តិការទូទាត់ឆ្នើម (STP) ប្រចាំឆ្នាំ២០២៤ ពី The Bank of New York Mellon (BNY)។ ពានរង្វាន់នេះ បង្ហាញពីសមិទ្ធផលដ៏ល្អឥតខ្ចោះរបស់ធនាគារ អេស៊ីលីដា ក្នុងការបម្រើសេវាទូទាត់ សម្រាប់ទម្រង់បែបបទ MT103/MT202។
- នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២៥ ធនាគារ អេស៊ីលីដា មានមោទនភាពដែលទទួលបានរង្វាន់ជាស្ថាប័នល្អឆ្នើម ចំនួន ២ ពីនិយ័តករមូលបត្រកម្ពុជា និងផ្សារមូលបត្រកម្ពុជា គឺរង្វាន់អភិបាលកិច្ចសាជីវកម្មល្អឆ្នើម និងរង្វាន់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រឆ្នើម ប្រចាំឆ្នាំ២០២៥។
- នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២៥ ធនាគារ អេស៊ីលីដា មានមោទនភាពបានជាប់ជាក្រុមហ៊ុន ដែលមានការបង្ហាញព័ត៌មានសាជីវកម្មឆ្នើម ប្រចាំឆ្នាំ២០២៥ ក្រោមការវាយតម្លៃយ៉ាងល្អិតល្អន់ពីនិយ័តករមូលបត្រកម្ពុជា និងផ្សារមូលបត្រកម្ពុជា។
- នៅថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៥ ធនាគារ អេស៊ីលីដា បានប្រកាសជាផ្លូវការ ចុះហត្ថលេខាលើកិច្ចសហប្រតិបត្តិការ ជាមួយក្រុមហ៊ុន NPCI International Payments Limited (NIPL) ដែលជាក្រុមហ៊ុនដៃគូអន្តរជាតិរបស់សាជីវកម្មទូទាត់រូបិយបណ្ណជាតិនៃប្រទេសឥណ្ឌា (NPCI)។ ធនាគារ អេស៊ីលីដា ត្រូវបានជ្រើសរើសដោយធនាគារជាតិ នៃ កម្ពុជា ក្នុងការធ្វើជាធនាគារទំនាក់ទំនងសម្រាប់បណ្តាញនៃការទូទាត់តាមរយៈបាគង (KHQR) នៅក្នុងប្រទេសកម្ពុជា ដែលនឹងសហការជាមួយ NIPL ដើម្បីបើកដំណើរការទទួលយកការទូទាត់ឆ្លងដែនតាមរយៈ Unified Payments Interface (UPI) នៅទូទាំងប្រទេសកម្ពុជា និង KHQR នៅទូទាំងប្រទេសឥណ្ឌា។ ភាពជាដៃគូនេះនឹងផ្តល់ជូនអ្នកធ្វើដំណើរជនជាតិឥណ្ឌា និងកម្ពុជា នូវភាពងាយស្រួលនៃ

ការទូទាត់តាមឃ្យូអរកូដយ៉ាងរហ័សទាន់ចិត្ត និងមានសុវត្ថិភាព នៅតាមតំបន់ទេសចរណ៍ ភោជនីយដ្ឋាន ហាងលក់ទំនិញ និងបណ្តាអាជីវកម្មផ្សេងៗទៀត។

- នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៥ ធនាគារ អេស៊ីលីដា បានទទួលលិខិតសរសើរ និងលើកទឹកចិត្ត ពីធនាគារជាតិ នៃ កម្ពុជា ជូនចំពោះធនាគារ អេស៊ីលីដា ភីអិលស៊ី ដែលបានគោរពតាមក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិ តាមរយៈការបំពេញភារកិច្ចដោយរៀបចំរបាយការណ៍ ជូនធនាគារជាតិ នៃ កម្ពុជា បានយ៉ាងខ្ជាប់ខ្ជួន និងទាន់ពេលវេលា ដើម្បីធានាបាននូវនិរន្តរភាពនៃវិស័យធនាគារនៃកម្ពុជា។
- នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៥ ធនាគារ អេស៊ីលីដា មានកិត្តិយសក្នុងការប្រកាសពីការទទួលបានលិខិតសរសើរពី **អគ្គទេសាភិបាល ធនាគារជាតិ នៃ កម្ពុជា** ដែលធនាគារ អេស៊ីលីដា ភីអិលស៊ី សម្រេចបានចំណាត់ថ្នាក់លេខ ១ ប្រចាំឆ្នាំ២០២៥ ក្នុងការផ្តល់ប្រាក់កម្ចី និងទទួលប្រាក់បញ្ញើ ជាប្រាក់រៀលនៅក្នុងវិស័យធនាគារនៃកម្ពុជា។
- នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៥ ធនាគារ អេស៊ីលីដា បានដាក់ឱ្យប្រើប្រាស់ជាផ្លូវការ **ប្រព័ន្ធទូទាត់ឆ្លងដែនតាមឃ្យូអរកូដ** នៅក្នុងប្រទេសកម្ពុជា **(ដំណាក់កាលទី២៖ ឡាវស្កេន ខេអេចឃ្យូអរកូដ)** ក្នុងគោលបំណងផ្សព្វផ្សាយជាសាធារណៈអំពីការពង្រីកវិសាលភាព និងការជំរុញការទូទាត់ជាឌីជីថល សំដៅពង្រឹងទំនាក់ទំនងសេដ្ឋកិច្ចរវាងប្រទេសកម្ពុជា និងប្រទេសឡាវ ព្រមទាំងរួមចំណែកលើកកម្ពស់វិស័យទេសចរណ៍នៃប្រទេសទាំងពីរ ជាពិសេសសម្រេចបាននូវទស្សនៈវិស័យរបស់អាស៊ាន ក្នុងការផ្សារភ្ជាប់ទំនាក់ទំនងរវាងប្រព័ន្ធទូទាត់ឌីជីថលនៅក្នុងសហគមន៍។ កិច្ចសហប្រតិបត្តិការនេះរៀបចំឡើងក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **លោកជំទាវ បណ្ឌិត ជា សិរី** អគ្គទេសាភិបាលធនាគារជាតិ នៃ កម្ពុជា និង **លោកជំទាវ Bounkham Vorachit** ទេសាភិបាលធនាគារកណ្តាលឡាវ។

# ផ្នែកទី២- ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

## ក- លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក

- **<u>ប្រតិបត្តិការក្នុងវិស័យធនាគារ</u>**

ត្រឹមដំណាច់ខែវិច្ឆិកា ឆ្នាំ២០២៥ ធនាគារពាណិជ្ជមានចំនួន៥៩ ធនាគារឯកទេសចំនួន០៧ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន៨៩ (គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើចំនួន០៤ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើចំនួន៨៥) ក្រុមហ៊ុនភតិសន្យាចំនួន១២ ការិយាល័យតំណាងធនាគារបរទេសចំនួន០៥ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ចំនួន៣០ គ្រឹះស្ថានឥណទានជនបទចំនួន៨៩ អ្នកដំណើរការតតិយភាគីចំនួន០៤ ក្រុមហ៊ុនចែករំលែកព័ត៌មានឥណទាន០១ និង ភ្នាក់ងារប្តូរប្រាក់ចំនួន៣.៣៩៥។ (Source: NBC Report)

- **<u>ប្រតិបត្តិការអាជីវកម្ម និងចំណែកទីផ្សាររបស់ធនាគារ អេស៊ីលីដា នៅក្នុងវិស័យធនាគារ</u>**

គិតត្រឹមដំណាច់ខែតុលា ឆ្នាំ២០២៥ ធនាគារ អេស៊ីលីដា មានចំណែកទីផ្សារសម្រាប់ប្រាក់បញ្ញើសន្សំចំនួន ១៣,៤៤% និងសម្រាប់ឥណទានចំនួន ១១,៨៥%។

គិតត្រឹមដំណាច់ខែធ្នូ ឆ្នាំ២០២៥ ធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួនទទួលបានលទ្ធផលសំខាន់ៗ ដូចខាងក្រោម៖

| លទ្ធផលសំខាន់ៗ | លទ្ធផលសម្រេចបាន | | |
|---|---|---|---|
| | ត្រីមាសទី៤ ឆ្នាំ២០២៥ | ឆ្នាំ២០២៤ | ឆ្នាំ២០២៣ |
| **សេវាឥណទាន** | | | |
| ចំនួនឥណទានសកម្ម | ៩៣៣.៩៦២ | ៧៣៣.៥៤៩ | ៦៦១.៩៤១ |
| សមតុល្យឥណទាន (លានរៀល) | ៣០.៦៣៧.០៤៣ | ២៨.៦៥៤.០៦៨ | ២៧.១៩៥.១២០ |

| លទ្ធផលសំខាន់ៗ | លទ្ធផលសម្រេចបាន | | |
|---|---|---|---|
| | ត្រីមាសទី៤ ឆ្នាំ២០២៥ | ឆ្នាំ២០២៤ | ឆ្នាំ២០២៣ |
| **សេវាបញ្ញើ-សន្សំ** | | | |
| ចំនួនគណនី | ៦.៤៧០.៤៧១ | ៥.៩២៥.០៨៦ | ៤.៥៥០.៥៨២ |
| សមតុល្យប្រាក់បញ្ញើ (លានរៀល) | ៣៧.៥៩៨.៨៧០ | ៣៣.៦៤៥.២០០ | ២៩.៥២៥.៦១៦ |
| **សេវាធនាគារអេឡិចត្រូនិក** | | | |
| **ប័ណ្ណអេធីអឹមអេស៊ីលីដា** | | | |
| ចំនួនប័ណ្ណបោះផ្សាយ | ១.៦៨២.៥៩៣ | ១.៨០២.៤១៨ | ១.៩៣៩.០៩៨ |
| ចំនួនប្រតិបត្តិការ | ១៣.៤៨៥.២៤៥ | ១៧.១០៧.៧៨៨ | ១៩.៨៥១.៨០១ |
| ទំហំទឹកប្រាក់ (លានរៀល) | ១២.៤៣២.៨០៦ | ១៥.៦៨៥.០០៦ | ១៧.១៤៥.៤១១ |
| **អេស៊ីស្ទូភើអេប** | | | |
| ចំនួនអ្នកប្រើប្រាស់ | ៥.៦៤៣.១៧៩ | ៤.៤១១.០៨០ | ៣.៤៥១.៦០៦ |
| ចំនួនប្រតិបត្តិការ | ១.៨៦៣.៩៣៨.១៧៥ | ៩២២.៧៩៣.៥១១ | ៣៧៣.០៣៦.៣៣៦ |
| ទំហំទឹកប្រាក់ (លានរៀល) | ៨៨២.៧១១.៤៨៩ | ៦៣១.០១២.៣៣៤ | ៣៨៣.០៤៣.៥៩៦ |
| **អេស៊ីលីដាអ៊ីនធើណែត** | | | |
| ចំនួនអ្នកប្រើប្រាស់ | ២៦.០២២ | ២៤.០៣៣ | ២៤.៨២៥ |
| ចំនួនប្រតិបត្តិការ | ៦.៨៣៨.៥៦៨ | ៥.០៣៧.១៤២ | ៣.៥២៩.២០៩ |
| ទំហំទឹកប្រាក់ (លានរៀល) | ៤៥.៣៩០.៤៧៣ | ៣៥.៣១៨.៥៧៨ | ២៦.៥២៩.៣៨១ |
| **អេស៊ីលីដាអ៊ីខុមមើស** | | | |
| ចំនួនដៃគូអាជីវកម្ម | ៣១១ | ១៦៤ | ៨៨ |
| ចំនួនប្រតិបត្តិការ | ៥.៦១៦.៥៥៧ | ៣.២៩៧.៣០៩ | ៣.៩៨៣.១៦៧ |
| ទំហំទឹកប្រាក់ (លានរៀល) | ២.២៣៣.៨៦៣ | ២.០១៦.៦០១ | ២.០១៩.០០១ |
| **ម៉ាស៊ីនអេធីអឹមអេស៊ីលីដា** | | | |
| ចំនួនម៉ាស៊ីន | ១.៥១២ | ១.៤១៦ | ១.៣១៤ |
| ចំនួនប្រតិបត្តិការ | ៧៥.៤៦២.៧៣៧ | ៦៩.៥៤៥.៤៨៧ | ៤១.៥៥៤.៩៩៣ |
| ទំហំទឹកប្រាក់ (លានរៀល) | ៩៣.៥៧៣.៥១២ | ៨៥.៥៤៩.៩៣៤ | ៤៦.៨០១.៩៨២ |
| **ម៉ាស៊ីនដាក់ប្រាក់បញ្ញើមានកាលកំណត់** | | | |
| ចំនួនម៉ាស៊ីន | ២៦ | ២៦ | ២៦ |
| ចំនួនប្រតិបត្តិការ | ៩៦ | ១៨៥ | ៣០៤ |

| លទ្ធផលសំខាន់ៗ | លទ្ធផលសម្រេចបាន | | |
|---|---|---|---|
| | ត្រីមាសទី៤ ឆ្នាំ២០២៥ | ឆ្នាំ២០២៤ | ឆ្នាំ២០២៣ |
| ទំហំទឹកប្រាក់ (លានរៀល) | ៩.២១៣ | ១១.០៧២ | ១៦.១៤៣ |
| **ម៉ាស៊ីនបើកគណនី និងបោះពុម្ពប័ណ្ណអេធីអឹម** | | | |
| ចំនួនម៉ាស៊ីន | ៩៦ | ៩៦ | ៩៦ |
| ចំនួនប្រតិបត្តិការ | ១០៩.៧៧០ | ១៥៤.៤៨០ | ១៣០.៩៨៧ |
| ទំហំទឹកប្រាក់ (លានរៀល) | - | ១ | ៥ |
| **ម៉ាស៊ីនទទួលកាបូបប្រាក់** | | | |
| ចំនួនម៉ាស៊ីន | ១៧ | ១៧ | ១៧ |
| ចំនួនប្រតិបត្តិការ | ៨៨.៩៩៦ | ៩០.០២៧ | ៨៨.៩០៨ |
| ទំហំទឹកប្រាក់ (លានរៀល) | ៣៣៩.៨៨៨ | ៤០១.៨១៤ | ៥០៦.៥៥០ |
| **ម៉ាស៊ីនឆូតកាតអេស៊ីលីដា** | | | |
| ចំនួនម៉ាស៊ីនឆូតកាត | ៦.៥០៦ | ៥.៥៥៣ | ៤.៧២៨ |
| ចំនួនប្រតិបត្តិការ | ១៥.៤៤៤.៤៣៣ | ៥.៦៨៣.២៤៧ | ១.៩០០.៤០០ |
| ទំហំទឹកប្រាក់ (លានរៀល) | ២.៣៨២.៩៣២ | ១.០៩៥.៥០៣ | ៦១៤.៤០៣ |
| **ឃ្យូអរ ពាណិជ្ជករ** | | | |
| ចំនួនពាណិជ្ជករ | ៧៩៩.៩១៨ | ៥៥៥.៥៥៤ | ៣៨២.២១៧ |
| ចំនួនប្រតិបត្តិការ | ១.០១៤.០២៦.៧៣៩ | ៤១៣.៩០៥.៦៦៥ | ១១០.១៤៨.៨៤៨ |
| ទំហំទឹកប្រាក់ (លានរៀល) | ២៩១.៧៨៤.៦៧១ | ១៤៥.០០២.៥៩១ | ៦៣.១៧៥.៧២០ |
| **ប័ណ្ណនិម្មិតអេស៊ីលីដា** | | | |
| ចំនួនប័ណ្ណនិម្មិត | ១២០.៦៦៥ | ៤៥.២៧៥ | ២៧.១០៦ |
| ចំនួនប្រតិបត្តិការ | ១.២៣០.៣៧២ | ៧៦៨.២៦០ | ១៨២.៣៧៦ |
| ទំហំទឹកប្រាក់ (លានរៀល) | ១៦៨.៤៣៦ | ៩៧.៣៩៦ | ១៨.៨១៨ |
| **ខ្សែអាយប៊ែង** | | | |
| ចំនួនខ្សែបោះផ្សាយ | ១០.៣៣៩ | ១០.៥១៣ | ១០.៦០៣ |
| ចំនួនប្រតិបត្តិការ | ២.៤២០ | ៤.៣៣៥ | ១២.៧១០ |
| ទំហំទឹកប្រាក់ (លានរៀល) | ២.៨៤៨ | ១២.៥៥៩ | ១៤.៥១១ |
| **បណ្ដាញប្រតិបត្តិការ និង បុគ្គលិក** | | | |
| **ធនាគារ អេស៊ីលីដា ភីអិលស៊ី** | | | |
| ចំនួនការិយាល័យ | ២៦៥ | ២៦៥ | ២៦៤ |

| លទ្ធផលសំខាន់ៗ | លទ្ធផលសម្រេចបាន | | |
|---|---|---|---|
| | ត្រីមាសទី៤ ឆ្នាំ២០២៥ | ឆ្នាំ២០២៤ | ឆ្នាំ២០២៣ |
| ចំនួនធនាគារស្វ័យប្រវត្តិ | ២២២ | ២០៦ | ១៧៧ |
| ចំនួនបុគ្គលិក | ១១.៨៥៩ | ១១.៩៧១ | ១២.០៤៥ |
| ក្រុមហ៊ុនបុត្រសម្ព័ន្ធ (ក្នុង និង ក្រៅប្រទេស) | | | |
| ចំនួនការិយាល័យ | ៥៦ | ៥៦ | ៥៦ |
| ចំនួនបុគ្គលិក | ១.៤២១ | ១.៤៨៣ | ១.៤៥៨ |

## ខ- រចនាសម្ព័ន្ធចំណូល

| ល.រ | ប្រភពចំណូល (លានរៀល) | ត្រីមាសទី៤ ឆ្នាំ២០២៥ | | ត្រីមាសទី៤ ឆ្នាំ២០២៤ | | ត្រីមាសទី៤ ឆ្នាំ២០២៣ | |
|---|---|---|---|---|---|---|---|
| | | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ១ | ចំណូលការប្រាក់ | ៩០៩.៣៩០ | ៩១,២៨% | ៨៤៦.៩៣៨ | ៩៤,៤១% | ៨០០.៩៥០ | ៩១,៦៣% |
| ២ | ចំណូលកម្រៃនិងជើងសា | ៤៦.៧៩៥ | ៤,៧០% | ៤៤.០៧៦ | ៤,៩១% | ៤៧.៩០២ | ៥,៤៨% |
| ៣ | ចំណូលផ្សេងៗសុទ្ធ | ៤០.០៣១ | ៤,០២% | ៦.០៥៧ | ០,៦៨% | ២៥.២៥០ | ២,៨៩% |
| | **ចំណូលសរុប** | **៩៩៦.២១៦** | **១០០%** | **៨៩៧.០៧១** | **១០០%** | **៨៧៤.១០២** | **១០០%** |

# ផ្នែកទី៣- របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មដោយសវនករឯករាជ្យ

សូមពិនិត្យមើលឧបសម្ព័ន្ធដែលបានភ្ជាប់មកជាមួយ
របាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានធ្វើសវនកម្មដោយសវនករឯករាជ្យ

## ផ្នែកទី៤- ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង

ការពិភាក្សា និងការវិភាគខាងក្រោមនេះផ្តោតសំខាន់លើលទ្ធផលប្រតិបត្តិការ និងលទ្ធផលហិរញ្ញវត្ថុដោយផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុចន្លោះពេលគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ដែលត្រូវបានធ្វើសវនកម្មដោយសវនករឯករាជ្យ។ របាយការណ៍ហិរញ្ញវត្ថុចន្លោះពេលត្រូវបានរៀបចំឡើងដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (“ស.រ.ទ.ហ.អ.ក”)។ មានតែសមាសធាតុសំខាន់ៗនៃរបាយការណ៍ហិរញ្ញវត្ថុចន្លោះពេល និងកត្តាសំខាន់ៗដែលប៉ះពាល់ដល់ប្រាក់ចំណេញរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ធនាគារ (“សម្ព័ន្ធធនាគារ”) ប៉ុណ្ណោះ ត្រូវបានយកមកធ្វើការពិភាក្សា និងវិភាគ។

## ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

### ១- ការវិភាគចំណូល

សម្ព័ន្ធធនាគារ មានប្រភពចំណូលធំៗចំនួនបីគឺ ចំណូលការប្រាក់ ចំណូលកម្រៃនិងជើងសា និងចំណូលផ្សេងៗសុទ្ធ។

- ចំណូលការប្រាក់៖ រួមមានចំណូលការប្រាក់ពីឥណទាននិងបុរេប្រទាន ចំណូលការប្រាក់ពីប្រាក់បញ្ញើនៅធនាគារផ្សេងៗ និងការវិនិយោគហិរញ្ញវត្ថុ។
- ចំណូលកម្រៃនិងជើងសា៖ រួមមានកម្រៃជើងសា កម្រៃជើងសាបានពីភ្នាក់ងារធានារ៉ាប់រង កម្រៃពីម៉ាស៊ីនអេធីអឹម កម្រៃពីការសងឥណទានមុនកាលកំណត់ កម្រៃពីសេវាប្រាក់បញ្ញើ កម្រៃពីសេវាធានា និងកម្រៃពីការបណ្តុះបណ្តាល។
- ចំណូលផ្សេងៗសុទ្ធ៖ រួមមានចំណេញពីការប្តូររូបិយប័ណ្ណ-សុទ្ធ ចំណេញពីការលក់ទ្រព្យសម្បត្តិនិងបរិក្ខារនិងភតិសន្យា ភាគលាភលើការវិនិយោគហិរញ្ញវត្ថុ និងចំណូលផ្សេងៗ។

### ២- ការវិភាគចំណូលតាមផ្នែក

| ល.រ | ប្រភពចំណូល (លានរៀល) | ត្រីមាសទី៤ ឆ្នាំ២០២៥ | | ត្រីមាសទី៤ ឆ្នាំ២០២៤ | | ត្រីមាសទី៤ ឆ្នាំ២០២៣ | |
|---|---|---|---|---|---|---|---|
| | | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ១ | ចំណូលការប្រាក់ | ៩០៩.៣៩០ | ៩១,២៨% | ៨៤៦.៩៣៨ | ៩៤,៤១% | ៨០០.៩៥០ | ៩១,៦៣% |
| ២ | ចំណូលកម្រៃនិងជើងសា | ៤៦.៧៩៥ | ៤,៧០% | ៤៤.០៧៦ | ៤,៩១% | ៤៧.៩០២ | ៥,៤៨% |
| ៣ | ចំណូលផ្សេងៗសុទ្ធ | ៤០.០៣១ | ៤,០២% | ៦.០៥៧ | ០,៦៨% | ២៥.២៥០ | ២,៨៩% |
| **ចំណូលសរុប** | | **៩៩៦.២១៦** | **១០០%** | **៨៩៧.០៧១** | **១០០%** | **៨៧៤.១០២** | **១០០%** |

ចំណូលសរុបនៅត្រីមាសទី៤ ឆ្នាំ២០២៥ បានកើនឡើងចំនួន ៩៩,១៥ ប៊ីលានរៀល ឬ ១១,០៥% បើប្រៀបធៀបទៅនឹងត្រីមាសទី៤ ឆ្នាំ២០២៤ ដែលការកើនឡើងទាំងនេះគឺដោយសារប្រសិទ្ធភាពនៃផលិតផល និងសេវាកម្មដ៏សម្បូរបែបរបស់ធនាគារក្នុងយុគសម័យឌីជីថល និងកំណើនអតិថិជន នៅត្រីមាសទី៤ ឆ្នាំ២០២៥។

### ៣- ការវិភាគគម្លាតចំណេញដុល

របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗរបស់សម្ព័ន្ធធនាគារ ត្រូវបានរៀបចំក្នុងទម្រង់ជារបាយការណ៍ដែលមិនបង្ហាញពីគម្លាតចំណេញដុលទេ។ ចំណូលការប្រាក់សុទ្ធដែលទទួលបានមកពីចំណូលការប្រាក់សរុបដកនឹងចំណាយការប្រាក់សរុប នឹងត្រូវយកមកបង្ហាញនៅក្នុងការវិភាគចំណេញ/(ខាត) មុនបង់ពន្ធ ដូចខាងក្រោម។

## ៤- ការវិភាគចំណេញ/(ខាត) មុនបង់ពន្ធ

| របាយការណ៍ចំណេញ ឬខាត (លានរៀល) | ត្រីមាសទី៤ ឆ្នាំ២០២៥ | ត្រីមាសទី៤ ឆ្នាំ២០២៤ | គម្លាត | |
|---|---|---|---|---|
| | | | ចំនួន | ភាគរយ |
| ចំណូលការប្រាក់ | ៩០៩.៣៩០ | ៨៤៦.៩៣៨ | ៦២.៤៥២ | ៧,៣៧% |
| ចំណាយការប្រាក់ | (៣០៧.១៧៣) | (៣៤០.៤២៧) | ៣៣.២៥៤ | (៩,៧៧%) |
| **ចំណូលការប្រាក់សុទ្ធ** | **៦០២.២១៧** | **៥០៦.៥១០** | **៩៥.៧០៧** | **១៨,៩០%** |
| ចំណូលកម្រៃនិងជើងសា | ៤៦.៧៩៥ | ៤៤.០៧៦ | ២.៧១៩ | ៦,១៧% |
| ចំណាយកម្រៃនិងជើងសា | (៣.៤៣៤) | (២.៦២៦) | (៨០៨) | ៣០,៧៧% |
| **ចំណូលកម្រៃនិងជើងសាសុទ្ធ** | **៤៣.៣៦០** | **៤១.៤៤៩** | **១.៩១១** | **៤,៦១%** |
| ការខាតបង់ឱនភាពនៃតម្លៃរបស់ឥណទាននិងបុរេប្រទាន ប្រាក់បញ្ញើនៅធនាគារផ្សេងៗ គណនីត្រូវទទួល និងមូលបត្រវិនិយោគផ្សេងៗ | (៨៦.១១៨) | (៥.៩៨៧) | (៨០.១៣១) | ១.៣៣៨,៤២% |
| (ការខាតបង់ឱនភាពនៃតម្លៃ)/ការកត់ត្រាត្រឡប់នៃការខាតបង់ឱនភាពនៃតម្លៃ របស់កិច្ចសន្យាក្រៅតារាងតុល្យការ | (៨៦០) | ២ | (៨៦២) | ៤៣.១០០% |
| **ការខាតបង់ឱនភាពនៃតម្លៃសុទ្ធ** | **(៨៦.៩៧៨)** | **(៥.៩៨៥)** | **(៨០.៩៩៣)** | **១.៣៥៣,២៧%** |
| **ចំណូលបន្ទាប់ពីការខាតបង់ឱនភាពនៃតម្លៃ** | **៥៥៨.៥៩៩** | **៥៤១.៩៧៥** | **១៦.៦២៤** | **៣,០៧%** |
| ចំណូលផ្សេងៗសុទ្ធ | ៤០.០៣១ | ៦.០៥៧ | ៣៣.៩៧៤ | ៥៦០,៩០% |
| ការខាតបង់ពីការកែប្រែមិនមែនហានិភ័យឥណទាន និងការខាតបង់ផ្សេងទៀត | (១៥.១៦០) | - | (១៥.១៦០) | - |
| ចំណាយប្រតិបត្តិការផ្សេងៗ | (៣៣៣.២៩៥) | (២៩៩.៨១២) | (៣៣.៤៨៣) | ១១,១៧% |
| **ចំណេញមុនចំណាយពន្ធលើប្រាក់ចំណេញ** | **២៥០.១៧៥** | **២៤៨.២១៩** | **១.៩៥៦** | **០,៧៩%** |

ការកើនឡើងនូវតម្រូវការទុនអាជីវកម្មរបស់អតិថិជន បានធ្វើឱ្យឥណទានរបស់សម្ព័ន្ធធនាគារ កើនឡើងចំនួន ៥១៥,៤៣ លានដុល្លារអាមេរិក ពីដំណាច់ឆ្នាំ២០២៤ ជាមួយនឹងប្រសិទ្ធភាពនៃផលិតផល និងសេវាកម្មដ៏សម្បូរបែបរបស់ធនាគារក្នុងយុគសម័យឌីជីថល និងកំណើនអតិថិជន នៅត្រីមាសទី៤ ឆ្នាំ២០២៥។

## ៥- ការវិភាគចំណេញ/(ខាត) ក្នុងការិយបរិច្ឆេទ

| របាយការណ៍ចំណេញ ឬខាត (លានរៀល) | ត្រីមាសទី៤ ឆ្នាំ២០២៥ | ត្រីមាសទី៤ ឆ្នាំ២០២៤ | គម្លាត | |
|---|---|---|---|---|
| | | | ចំនួន | ភាគរយ |
| **ចំណេញមុនចំណាយពន្ធលើប្រាក់ចំណេញ** | **២៥០.១៧៥** | **២៤៨.២១៩** | **១.៩៥៦** | **០,៧៩%** |
| ចំណាយពន្ធលើប្រាក់ចំណេញ | (៤៨.៩៧៨) | (៥៥.៥២៨) | ៦.៥៥០ | (១១,៨០%) |
| **ប្រាក់ចំណេញក្នុងការិយបរិច្ឆេទ** | **២០១.១៩៧** | **១៩២.៦៩២** | **៨.៥០៥** | **៤,៤១%** |

## ៦- ការវិភាគលទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ

| លទ្ធផលលម្អិតសរុប (លានរៀល) | ត្រីមាសទី៤ ឆ្នាំ២០២៥ | ត្រីមាសទី៤ ឆ្នាំ២០២៤ | គម្លាត | |
|---|---|---|---|---|
| | | | ចំនួន | ភាគរយ |
| **ប្រាក់ចំណេញក្នុងការិយបរិច្ឆេទ** | **២០១.១៩៧** | **១៩២.៦៩២** | **៨.៥០៥** | **៤,៤១%** |
| **លទ្ធផលចំណេញលម្អិតផ្សេងៗ៖** | | | | |
| ***ធាតុដែលនឹងមិនត្រូវបានចាត់ថ្នាក់ឡើងវិញទៅចំណេញ ឬខាត៖*** | | | | |
| លម្អៀងពីអត្រាប្តូរប្រាក់ | ៤.៧៩៣ | (៥៣.៥៧៣) | ៥៨.៣៦៦ | ១០៨,៩៥% |
| ***ធាតុដែលត្រូវ ឬអាចត្រូវបានចាត់ថ្នាក់ឡើងវិញនៅគ្រាបន្ទាប់ទៅចំណេញ ឬខាត៖*** | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ-ក្រុមហ៊ុនបុត្រសម្ព័ន្ធបរទេស | (៧.៩៦៨) | ៣១.៥៩៤ | (៣៩.៥៦២) | (១២៥,២២%) |
| ការវាស់វែងឡើងវិញលើផ្នែកដែលមានប្រសិទ្ធភាពរបស់ឧបករណ៍និស្សន្ទដែលកើតឡើងពីការការពារហានិភ័យលំហូរសាច់ប្រាក់ | (២.៣៨០) | (៤.២៥២) | ១.៨៧២ | ៤៤,០៣% |
| **លទ្ធផលចំណេញ/(ខាត)លម្អិតផ្សេងៗក្នុងការិយបរិច្ឆេទ** | **(៥.៥៥៤)** | **(២៦.២៣១)** | **២០.៦៧៧** | **៧៨,៨៣%** |
| **លទ្ធផលចំណេញលម្អិតសរុបក្នុងការិយបរិច្ឆេទ** | **១៩៥.៦៤២** | **១៦៦.៤៦០** | **២៩.១៨២** | **១៧,៥៣%** |

## ៧- ការវិភាគពីកត្តា និងនិន្នាការដែលប៉ះពាល់ស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុ

ធនាគារ អេស៊ីលីដា មានទំនុកចិត្តក្នុងការធ្វើឱ្យប្រសើរឡើងនូវប្រតិបត្តិការរបស់ខ្លួន ចំពេលការព្យាករកំណើនសេដ្ឋកិច្ចមានសញ្ញាល្អប្រសើរឡើង បន្ទាប់ពីបានកសាងកេរ្តិ៍ដំណែលដ៏រឹងមាំអស់រយៈពេលច្រើនជាង៣០ឆ្នាំកន្លងមកនេះ ធនាគារ អេស៊ីលីដា បានត្រៀមខ្លួនរួចជាស្រេចសម្រាប់ពេលអនាគត ហើយនឹងនៅតែបន្តចាក់គ្រឹះឱ្យកាន់តែរឹងមាំដើម្បីផ្តល់ជូននូវដំណោះស្រាយក្នុងវិស័យធនាគារឱ្យកាន់តែសម្បូរបែប ដើម្បីឆ្លើយតបទៅនឹងការផ្លាស់ប្តូរតម្រូវការផ្នែកហិរញ្ញវត្ថុរបស់អតិថិជនទាំងនៅក្នុង និងក្រៅប្រទេសកម្ពុជា។

បន្ទាប់ពីបំបែកព្រំដែនភូមិសាស្ត្រ ដោយការដាក់បញ្ចូលនូវហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងរូបវន្ត ធនាគារដែលបានបង្កើតឡើងនៅក្នុងស្រុកមួយនេះ កំពុងផ្តល់ជូននូវសេវាកម្មធនាគារសម្រាប់មូលដ្ឋានអតិថិជនចម្រុះដោយជោគជ័យ ដែលមានរាប់ចាប់តាំងពីសេវាធនាគារបុគ្គល និងសម្រាប់សាជីវកម្ម ទាំងនៅក្នុងទីក្រុង រហូតដល់តំបន់ជនបទ។ ជាមួយនឹងភាពលេចធ្លោក្នុងការផ្តល់ជូននូវសេវាកម្មហិរញ្ញវត្ថុដ៏សម្បូរបែប ដូចជាផ្តល់ប្រាក់កម្ចី ផ្ទេរប្រាក់ ប្រាក់បញ្ញើ ហិរញ្ញប្បទានពាណិជ្ជកម្ម អេស៊ីលីដាអ៊ីនធើណែត **អេស៊ីស្មាតអេប** និងសេវាសំខាន់ជាច្រើនទៀត គាំទ្រដោយហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងការិយាល័យរូបវន្តរបស់ខ្លួន ធនាគារ អេស៊ីលីដា កំពុងចូលរួមយ៉ាងសកម្មក្នុងការជួយដល់កសិករ តាមរយៈការផ្តល់ដើមទុនសម្រាប់ធ្វើស្រែចម្ការរបស់គាត់ ឬផ្តល់ទុនសម្រាប់សហគ្រាសធុនតូច និងមធ្យមជាដើម។ តាមរយៈការបង្រួមគម្លាតចំពោះការទទួលបានហិរញ្ញប្បទាន សព្វថ្ងៃនេះប្រជាជនកម្ពុជាច្រើនជាង ៨២០ពាន់នាក់ មានលទ្ធភាពប្រើប្រាស់សេវារបស់ធនាគារ អេស៊ីលីដា ដែលជាការជំរុញ និងលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុនៅព្រះរាជាណាចក្រកម្ពុជា។

បន្ទាប់ពីរយៈពេលច្រើនជាង៣០ឆ្នាំមកនេះ គេនឹងមើលឃើញ ធនាគារ អេស៊ីលីដា គឺជាធនាគារឌីជីថល ដែលមានវិស្វកម្ម គ្រប់គ្រងទិន្នន័យទំនើបទាន់សម័យ (Data Lakehouse) ប្រកបដោយគុណភាព សុវត្ថិភាព និងទំនុកចិត្ត។ ប្រព័ន្ធអេកូនៃបណ្តាញ ប្រកបដោយប្រសិទ្ធភាពរបស់ធនាគារនៅទូទាំងប្រទេស រួមមានម៉ាស៊ីន ATM ទីតាំងធនាគារស្វ័យប្រវត្តិ ម៉ាស៊ីនដក-ដាក់ប្រាក់ ម៉ាស៊ីនបើកគណនី និងបោះពុម្ពប័ណ្ណអេធីអឹម ម៉ាស៊ីនដាក់ប្រាក់បញ្ញើមានកាលកំណត់ កំពុងដើរតួជាកាតាលីករដ៏មានឥទ្ធិពលមួយ សម្រាប់រលកនៃកំណើនបន្ទាប់។

អនាគតរបស់ធនាគារនឹងកាន់តែរឹងមាំ ខណៈទំនុកចិត្តរបស់អាជីវកម្មលើកំណើនសេដ្ឋកិច្ចរបស់កម្ពុជា។ ការងើបឡើងវិញនៃ ការនាំចេញផ្នែកផលិតកម្ម និងការពង្រីកការនាំចេញទំនិញកសិកម្ម នឹងមានភាពល្អប្រសើរសម្រាប់ធនាគារ អេស៊ីលីដា ដោយសារ អ្នកទទួលកម្ចីភាគច្រើនមានអាជីវកម្មទាក់ទងនឹងកសិផល។ ដំណើរការអាជីវកម្មរបស់ធនាគារនៅឆ្នាំ២០២៥ មានដំណើរការល្អ ប្រសើរ ហើយត្រូវបានរំពឹងថានឹងបន្តកាន់តែប្រសើរឡើងនៅ២០២៦ ដោយសារធនាគារបានវិនិយោគយ៉ាងច្រើនទៅលើហេដ្ឋា រចនាសម្ព័ន្ធឌីជីថល សាងសង់មជ្ឈមណ្ឌលទិន្នន័យដ៏ធំមួយ ដែលមានសុវត្ថិភាពខ្ពស់ដើម្បីរក្សាទុកទិន្នន័យ។ ការសាងសង់ មជ្ឈមណ្ឌលការពារទិន្នន័យ (Disaster Recovery Data Center) នឹងជួយរក្សាទិន្នន័យនៅក្នុងបរិយាកាសដែលមានការ ការពារខ្ពស់។ ធនាគារមានទំនុកចិត្តចំពោះពេលអនាគត ជាមួយនឹងហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងផលិតផល-សេវាកម្ម ដែល នឹងកាន់តែមានភាពល្អប្រសើរ។

## ខ- កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ

### ១- ការវិភាគពីលក្ខខណ្ឌនៃតម្រូវការ និងការផ្គត់ផ្គង់

សម្ព័ន្ធធនាគារ ទទួលបានជោគជ័យនៅលើទីផ្សារអាស្រ័យដោយកត្តាពីរគឺៈ

- កំណើនសំពៀតឥណទាន ដោយសារតម្រូវការខ្ពស់នៅលើទីផ្សារលើផលិតផលឥណទានរបស់សម្ព័ន្ធធនាគារ ជាពិសេស សហគ្រាសធុនតូច និងមធ្យម។
- កំណើនប្រាក់បញ្ញើ-សន្សំ របស់សម្ព័ន្ធធនាគារ រួមជាមួយផលិតផល និងសេវាកម្មផ្សេងទៀត។

កត្តាទាំងពីរនេះត្រូវបានផ្សារភ្ជាប់ជាមួយនឹងការអភិវឌ្ឍឥតឈប់ឈរនៃប្រព័ន្ធឌីជីថលរបស់សម្ព័ន្ធធនាគារ ដែលផ្តល់ជូនអតិថិជន នូវផលិតផល និងសេវាកម្មហិរញ្ញវត្ថុប្រកបដោយភាពច្នៃប្រឌិត និងទាន់សម័យ។

សម្ព័ន្ធធនាគារ បាននឹងកំពុងតែអភិវឌ្ឍនូវហេដ្ឋារចនាសម្ព័ន្ធចម្រុះឱ្យកាន់តែទូលំទូលាយសម្រាប់ជាជម្រើសដ៏សម្បូរបែបជាមួយ នឹងការិយាល័យទាំង៣២១ តាមរយៈការផ្លាស់ប្តូរបន្តិចម្តងៗទៅជាមជ្ឈមណ្ឌលដែលអាចធ្វើស្វ័យប្រតិបត្តិការដែលមានទីតាំង ធនាគារស្វ័យប្រវត្តិចំនួន២២២ ព្រមទាំងមាន **ម៉ាស៊ីនអេធីអឹមអេស៊ីលីដា** ចំនួន១.៥១២ គ្រឿង **ម៉ាស៊ីនដាក់ប្រាក់បញ្ញើមានកាលកំណត់** ចំនួន២៦ គ្រឿង **ម៉ាស៊ីនបើកគណនី និងបោះពុម្ពប័ណ្ណអេធីអឹម** ចំនួន៩៦ គ្រឿង **ម៉ាស៊ីនទទួលកាបូបប្រាក់** ចំនួន១៧ គ្រឿង និង**ម៉ាស៊ីនឆូតកាត**ចំនួន៦.៥០៦ គ្រឿង។ ចំណុចគួរជាទីមោទនភាពគឺសម្ព័ន្ធធនាគារ បានបោះពុម្ពប័ណ្ណ**អេធីអឹមអេស៊ីលីដា** ចំនួន១,៦៨ លានប័ណ្ណជូនដល់អតិថិជន។ ទន្ទឹមនឹងនេះ **អេស៊ីស្ទ័រអេប** បានទទួលប្រជាប្រិយភាពយ៉ាងខ្លាំង ដែលចំនួននៃអ្នកចុះ ឈ្មោះប្រើប្រាស់បានកើនដល់ ៥,៦៤ លាននាក់ នៅដំណាច់ខែធ្នូ ឆ្នាំ២០២៥ នេះ ដែលអាចជួយឱ្យចរាចរសាច់ប្រាក់បានឆាប់រហ័សនៅ ក្នុងសេដ្ឋកិច្ច។

ការបង្កើនភាពងាយស្រួលដល់អតិថិជន និងពង្រឹងប្រព័ន្ធសុវត្ថិភាពអ៊ិនធើណែត គឺជាចំណុចដែលសម្ព័ន្ធធនាគារ ផ្តោតការយក ចិត្តទុកដាក់បំផុត។ ដើម្បីសម្រេចនូវវឌ្ឍនភាពគោលដៅដ៏រឹងមាំទាំងនេះ សម្ព័ន្ធធនាគារ នឹងបន្តលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធ បច្ចេកវិទ្យាព័ត៌មាន តាមរយៈការវិនិយោគលើបច្ចេកវិទ្យាទំនើបចុងក្រោយ ពង្រឹងសមត្ថភាពធនធានមនុស្ស ព្រមទាំងពង្រីកនិងកែ លម្អដំណើរការអាជីវកម្ម។ ជាយុទ្ធសាស្ត្រ សម្ព័ន្ធធនាគារកំពុងអភិវឌ្ឍប្រព័ន្ធទូទាត់ដែលអាចឱ្យដៃគូទាំងក្នុង និងក្រៅប្រទេសអាច ភ្ជាប់ប្រព័ន្ធនេះដើម្បីបម្រើអតិថិជនទៅវិញទៅមក និងឆ្លងព្រំដែន។ ប្រព័ន្ធនេះមិនត្រឹមតែផ្តល់អត្ថប្រយោជន៍ដោយផ្ទាល់ដល់អតិថិជន ដ៏ឆ្លាតវៃរបស់យើងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដៃគូអាជីវកម្មរបស់ពួកគាត់ផងដែរ។ យើងខ្ញុំទទួលស្គាល់ថាអតិថិជន និងដៃគូអាជីវកម្ម ទាំងអស់គឺជាបណ្តាញតភ្ជាប់ដ៏មានសារសំខាន់សម្រាប់ពង្រីកសេវាកម្មរបស់សម្ព័ន្ធធនាគារ និងរីកចម្រើនជាមួយគ្នា។

**អេស៊ីស្ម៉ាតអេប** ត្រូវបានកែលម្អយ៉ាងទូលំទូលាយ និងផ្លាស់ប្តូររូបរាងថ្មី កាន់តែទំនើប ងាយស្រួល និងមានសុវត្ថិភាពខ្ពស់ ជាមួយនឹងមុខងារពិសេសៗជាច្រើន។ ឥឡូវនេះ អតិថិជនទាំងអស់អាចធ្វើប្រតិបត្តិការប្រាក់បញ្ញើ-សន្សំ (សំចៃ ចរន្ត និងមានកាលកំណត់) តាមរយៈ **អេស៊ីស្ម៉ាតអេប** បានភ្លាមៗ ថែមទាំងទទួលបានការប្រាក់ខ្ពស់ទៀតផង។

**ខេអេចឃ្យូអរកូដ (KHQR Code)** ផ្តល់នូវភាពងាយស្រួលជាងមុនជូនដល់អ្នកប្រើប្រាស់ក្នុងការធ្វើប្រតិបត្តិការទូទាត់ថ្លៃទំនិញ និងសេវាកម្មផ្សេងៗប្រកបដោយប្រសិទ្ធភាព សុវត្ថិភាព និងទំនុកចិត្តខ្ពស់ រវាងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ដែលជាសមាជិករបស់កម្មវិធីបាគង (**Bakong App**)។

**អេស៊ីស្ម៉ាតអេប** ផ្តល់ភាពងាយស្រួលដល់អ្នកប្រើប្រាស់ក្នុងការស្កេនឃ្យូអរកូដពីគ្រប់ទីកន្លែង សម្រាប់ការទូទាត់ដោយមិនគិតថ្លៃនៅប្រទេសថៃ វៀតណាម ឡាវ ជប៉ុន សិង្ហបុរី និងម៉ាឡេស៊ី។ នេះជាភាពជោគជ័យថ្មីមួយទៀតរបស់ប្រព័ន្ធបាគង និងធនាគារអេស៊ីលីដា ដែលជាសមាជិករបស់បាគង។

### ២- ការវិភាគពីការឡើងចុះនៃថ្លៃវត្ថុធាតុដើម

ធនាគារ អេស៊ីលីដា ភីអិលស៊ី ប្រតិបត្តិការក្នុងវិស័យសេវាកម្ម ដែលការឡើងចុះនៃថ្លៃវត្ថុធាតុដើមមិនអាចអនុវត្តបានចំពោះធនាគារឡើយ។

### ៣- ការវិភាគលើពន្ធ

ធនាគារ អេស៊ីលីដា ភីអិលស៊ី និងក្រុមហ៊ុនបុត្រសម្ព័ន្ធ ស្ថិតនៅក្រោមច្បាប់ស្តីពីពន្ធដារនៃប្រទេសនីមួយៗ ដូច្នេះធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធមានកាតព្វកិច្ចបង់ពន្ធតាមការកំណត់របស់អាជ្ញាធរពន្ធដារនីមួយៗ។

ការបង់ពន្ធជូនអគ្គនាយកដ្ឋានពន្ធដារមិនត្រឹមតែជាកាតព្វកិច្ច និងការទទួលបានវិញ្ញាបនបត្រអនុលោមភាពសារពើពន្ធប្រភេទ **"មាស"** ពីអគ្គនាយកដ្ឋានពន្ធដារសម្រាប់ឆ្នាំជាប់ពន្ធ**២០២៤** ដល់**២០២៥** ប៉ុណ្ណោះទេ ប៉ុន្តែជាការចូលរួមចំណែកក្នុងសង្គម និងកំណើនសេដ្ឋកិច្ចផងដែរ។

ចំណូលពន្ធគឺជាប្រភពចំណូលដ៏សំខាន់បំផុតសម្រាប់ប្រទេស។ រដ្ឋាភិបាលប្រមូលពន្ធកាន់តែច្រើន ការចូលរួមវិភាគទានកាន់តែច្រើនដល់ការអភិវឌ្ឍប្រទេស។ ធនាគារ អេស៊ីលីដា ភីអិលស៊ី មានមោទនភាពដែលអាចចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាយើង។

### ៤- ការវិភាគលើធាតុដែលខុសពីធម្មតា និងធាតុវិសាមញ្ញ

សម្ព័ន្ធធនាគារ មិនមានធាតុ ប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលខុសពីធម្មតាជាសារវន្តនោះទេ។ ទោះជាយ៉ាងណាក៏ដោយ សេដ្ឋកិច្ចពិភពលោកបានជួបប្រទះនឹងបញ្ហាប្រឈមជាច្រើន រួមជាមួយនឹងការកើនឡើងអតិផរណា ភាពតានតឹងភូមិសាស្ត្រនយោបាយ និងការបិទព្រំដែនកម្ពុជា-ថៃ ដែលបានរំខានដល់ពាណិជ្ជកម្មឆ្លងដែន អាចជះឥទ្ធិពលដល់សមត្ថភាពសងត្រលប់មកវិញរបស់អតិថិជន ដែលគុណភាពឥណទានរបស់សម្ព័ន្ធធនាគារ អាចរងផលប៉ះពាល់បន្តិចបន្តួច។

## គ- ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

ដើម្បីចូលរួមគាំទ្រការរីកលូតលាស់អាជីវកម្មរបស់អតិថិជន សម្ព័ន្ធធនាគារ បានផ្តល់អត្រាការប្រាក់មានភាពប្រកួតប្រជែងខ្លាំងចំពោះការស្នើសុំឥណទានថ្មីគ្រប់ប្រភេទ និងដោយកាន់តែមានភាពងាយស្រួល អតិថិជនទាំងអស់អាចដាក់សំណើសុំឥណទានតាមរយៈ **អេស៊ីស្ម៉ាតអេប**។ ជាលទ្ធផល សមតុល្យឥណទានដុលសរុបនៅដំណាច់ត្រីមាសទី៤ ឆ្នាំ២០២៥ មានការកើនឡើងចំនួន ១.៩៨២,៩៧ ប៊ីលានរៀល ឬ ៦,៩២% ធៀបនឹងដំណាច់ត្រីមាសទី៤ ឆ្នាំ២០២៤។

## ឃ- ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ

នៅត្រីមាសទី៤ ឆ្នាំ២០២៥ អត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិកមានចន្លោះពី ៤.០១២ ទៅ ៤.០២៣ រៀល ក្នុងមួយដុល្លារអាមេរិក បានឡើងថ្លៃគួរឱ្យកត់សម្គាល់ ធៀបទៅនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ដែលស្ថិតក្នុងចន្លោះពី ៤.០២៥ ទៅ

៤.០៦៦ រៀល ក្នុងមួយដុល្លារអាមេរិក។ ប្រាក់រៀលបន្តមានស្ថិរភាពល្អប្រសើរ ព្រមទាំងមាននិន្នាការឡើងថ្លៃទៀតផង ដោយសារកំណើនតម្រូវការប្រាក់រៀល សម្រាប់ប្រើប្រាស់ក្នុងវិស័យកសិកម្ម ការទូទាត់អេឡិចត្រូនិក ការបង់ពន្ធ និងជាប្រភពដើមទុនសម្រាប់ផ្តល់កម្ចីដោយគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។ ជាពិសេសគឺការបន្តលើកកម្ពស់ និងការគាំទ្រពីធនាគារជាតិ នៃ កម្ពុជា។ ប្រមើលទៅខាងមុខ តម្លៃប្រាក់រៀលត្រូវបានរំពឹងថានឹងនៅតែបន្តមានស្ថិរភាពដែលជំរុញដោយតម្រូវការទីផ្សារ និងនិន្នាការផ្គត់ផ្គង់ការងើបឡើងវិញបន្តិចម្តងៗនៃសកម្មភាពសេដ្ឋកិច្ច និងទំនុកចិត្តរបស់សាធារណជនលើប្រាក់រៀល ជាពិសេសការគាំទ្រពីធនាគារជាតិ នៃ កម្ពុជា ដោយបានតាមដានយ៉ាងដិតដល់នូវតម្លៃរបស់ប្រាក់រៀល ចាត់ចែងរក្សាអត្រាប្តូរប្រាក់រៀល ដើម្បីរក្សាស្ថិរភាពតម្លៃរូបិយវត្ថុជាតិ និងសមភាពអំណាចទិញ និងបន្តអនុវត្តគោលនយោបាយរូបិយវត្ថុជាបន្តបន្ទាប់។

ចំពោះធនាគារ អេស៊ីលីដា បានវាស់វែង ត្រួតពិនិត្យ និងគ្រប់គ្រងស្ថានភាពរូបិយប័ណ្ណចំហជាប្រចាំថ្ងៃ ដោយប្រតិបត្តិបានយ៉ាងត្រឹមត្រូវ និងគ្រប់គ្រាន់ អនុវត្តតាមបទប្បញ្ញត្តិរបស់ធនាគារជាតិ នៃ កម្ពុជា និងគោលនយោបាយហានិភ័យផ្ទៃក្នុងរបស់ខ្លួន ដូចនេះមិនមានផលប៉ះពាល់ជាសារវន្តដល់អាជីវកម្មរបស់ធនាគារឡើយ។

នៅក្នុងត្រីមាសទី៤ ឆ្នាំ២០២៥ ធនាគារកណ្តាលអាមេរិក បានទម្លាក់អត្រាការប្រាក់របស់ខ្លួន មកនៅត្រឹមចន្លោះពី ៣,៥០% ទៅ ៣,៧៥% ស្របតាមការរំពឹងទុក។ ទោះជាយ៉ាងណាក៏ដោយ មិនមានផលប៉ះពាល់ជាសារវន្តដល់ធនាគារ អេស៊ីលីដាឡើយ ដោយហេតុថាធនាគារបានដំណើរការប្រតិបត្តិការ ដោយការផ្គូផ្គងផ្នែកទាំងពីរនៃទ្រព្យសកម្ម និងបំណុល លើមូលដ្ឋានអត្រាការប្រាក់ថេរ និងត្រួតពិនិត្យជាប្រចាំ ដើម្បីចាត់វិធានការសមស្រប និងទាន់ពេលវេលាដែលអាចជៀសវាងផលប៉ះពាល់ដល់អាជីវកម្មរបស់ខ្លួន។

ចំពោះប្រតិបត្តិការជួញដូរនានា ដែលមានទម្រង់ជាទំនិញ (Commodities) ធនាគារមិនមានផ្តល់សេវាទាក់ទងនឹងវិស័យបែបនេះទេ ដូច្នេះមិនមានផលប៉ះពាល់ដល់ធនាគារឡើយ។

## ង- ផលប៉ះពាល់នៃអតិផរណា

អត្រាអតិផរណារួមនាឆ្នាំ២០២៥ បានកើនឡើងដល់ ២,៥% បន្ទាប់ពីបានថយចុះមកកម្រិតទាបបំផុតនាឆ្នាំ២០២៤ ក្នុងអត្រា ០,៨% ក្នុងរយៈពេលជាង ១ ទសវត្សរ៍ចុងក្រោយនេះ។ ការកើនឡើងនេះ ជាចម្បងបណ្តាលមកពីមូលដ្ឋានគណនាទាប និងការកើនឡើងនៃថ្លៃក្រុមម្ហូបអាហារ កាលពីដើមឆ្នាំ២០២៥ ខណៈដែលការបន្តធ្លាក់ថ្លៃប្រេងឆៅពិភពលោកបានជួយបន្ថយសម្ពាធអតិផរណា។ គួរកត់សម្គាល់ផងដែរថា ជម្លោះព្រំដែនកម្ពុជា-ថៃ ដែលនាំឱ្យមានការបិទព្រំដែនបានរាំងស្ទះដល់ការនាំចូលទំនិញពីប្រទេសថៃតាមផ្លូវគោក និងការហាមឃាត់ការនាំចូលទំនិញមួយចំនួនពីថៃ បាននាំឱ្យថ្លៃទំនិញមួយចំនួនតូចកើនបន្តិច និងក្នុងរយៈពេលខ្លីប៉ុណ្ណោះ ជាពិសេសនៅក្នុងតំបន់ព្រំដែនខ្មែរ-ថៃ។ ទំនិញទាំងនោះត្រូវបានជំនួសយ៉ាងឆាប់រហ័សដោយទំនិញក្នុងស្រុក និងទំនិញនាំចូលពីប្រទេសផ្សេង។

## ច- គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រាជរដ្ឋាភិបាល

- <u>**គោលនយោបាយសេដ្ឋកិច្ច៖**</u>

ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចកម្ពុជាបន្តរក្សាបានស្ថិរភាព ដែលឆ្លុះបញ្ចាំងតាមរយៈតុល្យភាពខាងក្នុង និងខាងក្រៅ។ សេដ្ឋកិច្ចកម្ពុជាត្រូវបានប៉ាន់ស្មានថាអាចសម្រេចបានកំណើន ៥% នាឆ្នាំ២០២៥ ដែលគាំទ្រជាចម្បងដោយកំណើនការនាំចេញវិស័យកម្មន្តសាល។ យ៉ាងណាមិញ អត្រានេះមានកម្រិតទាបជាងការរំពឹងទុក ដោយសារការធ្លាក់ចុះនៃចំនួនទេសចរ។ អត្រាអតិផរណាមានកម្រិត ២,៥% ដែលបណ្តាលមកពីមូលដ្ឋានគណនាទាប និងការកើនឡើងនៃថ្លៃម្ហូបអាហារ ខណៈថ្លៃប្រេងឆៅពិភពលោកបានបន្តថយចុះ។ អត្រាប្តូរប្រាក់មានស្ថិរភាពល្អប្រសើរក្នុងកម្រិតមធ្យម ៤.០១១ រៀល ក្នុងមួយដុល្លារអាមេរិក ដោយប្រាក់រៀលបានឡើងថ្លៃជាមធ្យម ១,៥% ធៀបនឹងឆ្នាំ២០២៤។ ជញ្ជីងទូទាត់មានអតិរេក ៨៨១,៣ លានដុល្លារអាមេរិក ដែលត្រូវបានគាំទ្រដោយលំហូរចូលសុទ្ធនៃគណនីហិរញ្ញវត្ថុ។ ទទ្រីមនេះទុនបម្រុងអន្តរជាតិបានកើនឡើងដល់ ២៧,៥ ប៊ីលានដុល្លារអាមេរិក ដែលស្មើនឹង ៨ខែ នៃការនាំចូលទំនិញនិងសេវាសម្រាប់គ្រាបន្ទាប់។[១]

ស្របគ្នានេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក៏បានព្យាករផងដែរថា សេដ្ឋកិច្ចកម្ពុជានឹងកើនឡើងក្នុងអត្រា ៦,៣% ក្នុងឆ្នាំ២០២៥ នេះបើយោងតាមរបាយការណ៍ថវិកាសង្ខេបសម្រាប់ឆ្នាំសារពើពន្ធ២០២៥ ដែលចេញផ្សាយដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF)។ យោងតាមការវាយតម្លៃនៃក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមរបស់រាជរដ្ឋាភិបាល កំណើននេះត្រូវបានគេរំពឹងថា

នឹងធ្វើឱ្យតម្លៃផលិតផលក្នុងស្រុកសរុប (GDP) បច្ចុប្បន្នកើនឡើងដល់ប្រហែល ២០៩.១៦៣ ប៊ីលានរៀល ស្មើនឹងប្រមាណ ៥១,៣៩ ប៊ីលានដុល្លារអាមេរិក។ ទន្ទឹមនឹងនេះ GDP សម្រាប់មនុស្សម្នាក់ត្រូវបានគេរំពឹងថានឹងឈានដល់ ២.៩២៤ ដុល្លារអាមេរិក។ តាមការព្យាករ កំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាក្នុងឆ្នាំ២០២៥ នឹងត្រូវបានគាំទ្រជាចម្បងដោយវិស័យសំខាន់ៗដូចជា ឧស្សាហកម្ម សេវាកម្ម និងកសិកម្ម។ [២]

យោងតាមព័ត៌មានដែលបានចុះផ្សាយរបស់ស្ថាប័នល្បីល្បាញមួយចំនួននៅបន្តព្យាករ GDP ឆ្នាំ២០២៥ របស់កម្ពុជាផងដែរ។ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) រាជធានីភ្នំពេញ (ថ្ងៃទី៩ ខែមេសា ឆ្នាំ២០២៥)៖ កម្ពុជារំពឹងថានឹងរក្សាបាននូវគន្លងកំណើនសេដ្ឋកិច្ចប្រកបដោយស្ថិរភាពនៅឆ្នាំ២០២៥ និងឆ្នាំ២០២៦ ដែលជំរុញដោយតម្រូវការខាងក្រៅសម្រាប់ទំនិញផលិត និងការបន្តស្ទុះងើបឡើងវិញក្នុងវិស័យទេសចរណ៍ នេះបើយោងតាមការចេញផ្សាយចុងក្រោយនៃរបាយការណ៍សេដ្ឋកិច្ចរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។ ទស្សនវិស័យអភិវឌ្ឍន៍អាស៊ី (ADO) ខែមេសា ឆ្នាំ២០២៥ ប៉ាន់ប្រមាណថា ផលិតផលក្នុងស្រុកសរុបនឹងកើនឡើង ៦,១% ក្នុងឆ្នាំ២០២៥ និង ៦,២% ក្នុងឆ្នាំ២០២៦ បន្ទាប់ពីកើនឡើង ៦% ក្នុងឆ្នាំ២០២៤។ ទោះជាយ៉ាងណាក៏ដោយ ហានិភ័យធ្លាក់ចុះចំពោះទស្សនវិស័យបានកើនឡើងដោយសារតែភាពមិនប្រាកដប្រជាជាសកល រួមទាំងគោលនយោបាយពាណិជ្ជកម្មនៅសហរដ្ឋអាមេរិក អស្ថិរភាពនៅក្នុងវិស័យអចលនទ្រព្យរបស់សាធារណរដ្ឋប្រជាមានិតចិន និងភាពតានតឹងភូមិសាស្ត្រនយោបាយដែលកំពុងបន្តប៉ះពាល់ដល់ខ្សែច្រវាក់ផ្គត់ផ្គង់។ [៣]

មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF)៖ សេដ្ឋកិច្ចកម្ពុជាបានបន្តងើបឡើងវិញ បានព្យាករថា GDP ៦,០% នៅឆ្នាំ២០២៤ ៤,៨% នៅឆ្នាំ២០២៥ និង ៤,០% ក្នុងឆ្នាំ២០២៦ ដោយយោងតាមការផ្សព្វផ្សាយលើគេហទំព័ររបស់ពួកគេ។ [៤]

ធនាគារពិភពលោក (WB) ភ្នំពេញ (ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៥) – សេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករថានឹងកើនឡើង ៤,៨% នៅឆ្នាំ២០២៥ ដោយធ្លាក់ចុះពី ៦% នៅឆ្នាំ២០២៤ ដោយសារផលប៉ះពាល់ក្នុងស្រុក និងខាងក្រៅបានជះឥទ្ធិពលដល់សកម្មភាពសេដ្ឋកិច្ច។ គោលនយោបាយសារពើពន្ធ និងរូបិយវត្ថុដ៏ប្រុងប្រយ័ត្ន រួមជាមួយនឹងការកែទម្រង់រចនាសម្ព័ន្ធដែលមានគោលដៅនឹងបន្តមានសារៈសំខាន់ដើម្បីទប់ស្កាត់ការធ្លាក់ចុះ និងពង្រឹងភាពធន់នៃសេដ្ឋកិច្ច។ [៥]

- **គោលនយោបាយសារពើពន្ធ៖**

សម្រាប់ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបានដាក់ចេញនូវវិធានការសំខាន់ៗ និងជាយុទ្ធសាស្ត្រសំខាន់ៗដូចតទៅ៖

(១) បន្តពង្រឹងការផ្សព្វផ្សាយ និងការអនុវត្តប្រកបដោយការយកចិត្តទុកដាក់នូវវិធានការលើកទឹកចិត្ត និងសម្រួលផ្នែកពន្ធដារជូនវិស័យឯកជននាពេលកន្លងមក និងក្នុងក្របខ័ណ្ឌវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជនលើកទី១៩ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចធិបតី នាយករដ្ឋមន្ត្រី** កាលពីថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៣។

(២) បន្តរៀបចំ និង/ឬធ្វើបច្ចុប្បន្នភាពលិខិតបទដ្ឋានគតិយុត្ត (ប្រកាស សេចក្តីណែនាំ និង/ឬសេចក្តីជូនដំណឹង) ក្នុងការអនុវត្តនូវវិធានការលើកទឹកចិត្ត និងការសម្រួលផ្នែកពន្ធដារ ដែលរាជរដ្ឋាភិបាលបានដាក់ចេញ ព្រមទាំងបន្តពង្រឹងការអនុវត្តប្រកបដោយការយកចិត្តទុកដាក់តាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់**សម្តេចធិបតី នាយករដ្ឋមន្ត្រី** ដាក់ចេញកន្លងមកក្នុងការពង្រឹងគុណភាពនៃការផ្តល់សេវា និងប្រសិទ្ធភាពការងារ។

(៣) បន្តពង្រឹងការយកចិត្តទុកដាក់ខ្ពស់លើគុណភាពនៃការផ្តល់សេវា និងលើកកម្ពស់ប្រសិទ្ធភាពការងាររបស់ខ្លួន ស្របតាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់**សម្តេចធិបតី នាយករដ្ឋមន្ត្រី** ដោយប្រកាន់ខ្ជាប់នូវអភិក្រមការងារ ៤ ប្រការរបស់**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

(៤) រៀបចំនិងដាក់ឱ្យប្រើប្រាស់នូវកម្មវិធី e-Administration ដែលនឹងក្លាយជាឧបករណ៍ទំនើប ដើម្បីគាំទ្ររាល់ការផ្តល់សេវាអ្នកជាប់ពន្ធដែលផ្តល់ភាពងាយស្រួលដល់អ្នកជាប់ពន្ធ និងសាធារណជនក្នុងការដាក់លិខិតរដ្ឋបាលនានាតាមប្រព័ន្ធអេឡិចត្រូនិក មករដ្ឋបាលសារពើពន្ធដើម្បីដំណើរការឯកសារជូន។

(៥) បន្តធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធស្របតាមចក្ខុវិស័យរបស់អគ្គនាយកដ្ឋានពន្ធដារ ក្នុងការប្រែក្លាយខ្លួនទៅជារដ្ឋបាលសារពើពន្ធទំនើបជំនាន់ ៣.០ (Tax Administration 3.0) ហើយដើម្បីសម្រេចបាននូវចក្ខុវិស័យនេះ អគ្គនាយកដ្ឋានពន្ធដារ សូមគោរពស្នើសុំការគាំទ្រដ៏ខ្ពង់ខ្ពស់ពីឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី ដើម្បីជំរុញឱ្យក្រសួង-ស្ថាប័នពាក់ព័ន្ធចូលរួមធ្វើទំនើបកម្មតាមសមត្ថកិច្ចរៀងៗខ្លួន។

(៦) បន្តធ្វើទំនើបកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងកម្មវិធីប្រកបដោយស្មារតីបុរេសកម្មតាមរយៈការអភិវឌ្ឍនិងធ្វើបច្ចុប្បន្នភាព បន្តវិនិយោគនិងអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រ និងពង្រឹងសមត្ថភាពមុខងារវិភាគទិន្នន័យបន្ថែមទៀត ដើម្បីបន្តជំរុញបង្កើនកម្រិតអនុលោមភាពសារពើពន្ធ ដោយធ្វើយ៉ាងណាឱ្យងាយស្រួលក្នុងការបំពេញកាតព្វកិច្ចពន្ធដារ ប៉ុន្តែពិបាកក្នុងការគេចវេះតាមរយៈការបន្តអភិវឌ្ឍបន្ថែមនូវមុខងារមួយចំនួន តាមធាតុចូលដែលទទួលបានពីអ្នកប្រើប្រាស់ពីគ្រប់មជ្ឈដ្ឋានដើម្បីឱ្យកាន់តែមានភាពគ្រប់ជ្រុងជ្រោយនិងងាយស្រួលក្នុងការប្រើប្រាស់។

(៧) បន្តសហការជាមួយក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ដើម្បីរៀបចំនិយាមនីតិវិធីប្រតិបត្តិការងារ (SOP) ស្តីពីការជូនវិញ្ញាបនបត្រសម្គាល់អចលនវត្ថុ ដែលទទួលបានការលើកលែងពន្ធ និងស្នើសុំទិន្នន័យអចលនទ្រព្យដែលអាចប្រើប្រាស់បានសម្រាប់ប្រមូលពន្ធប្រថាប់ត្រា ពន្ធលើអចលនទ្រព្យ និងពន្ធលើចំណេញមូលធន នាពេលខាងមុខក្នុងករណីមានការសម្រេចឱ្យអនុវត្ត។

(៨) បន្តចូលរួមយ៉ាងសកម្មក្នុងក្របខ័ណ្ឌក្រុមសិក្សាស្រាវជ្រាវ ឬកិច្ចសហការអន្តរជាតិនានា ក្នុងគោលដៅពិភាក្សា ចែករំលែក និងដកស្រង់បទពិសោធន៍ពីបណ្តារដ្ឋបាលសារពើពន្ធ និងស្ថាប័នអន្តរជាតិធំៗនានា ជាពិសេសសិក្សាពីបច្ចេកវិទ្យាថ្មីៗ ក្នុងវិស័យពន្ធដារ និងឧត្តមានុវត្តន៍នៃការប្រមូលចំណូល មានជាអាទិ៍ ក្រុមសិក្សាស្តីពីរដ្ឋបាលសារពើពន្ធអាស៊ីប៉ាស៊ីហ្វិក និងការសិក្សាស្រាវជ្រាវ (SGATAR) ក្រុមការងារគំនិតផ្តួចផ្តើមខ្សែក្រវាត់និងផ្លូវសម្រាប់កិច្ចសហប្រតិបត្តិការពន្ធដារ (BRITACOM) និងវេទិការដ្ឋបាលសារពើពន្ធ (Forum on Tax Administration - FTA) ជាដើម។

(៩) បន្តជំរុញរៀបចំឱ្យបានបញ្ចប់នូវឯកសារលិខិតបទដ្ឋានគតិយុត្តគាំទ្រដល់ច្បាប់ស្តីពីសារពើពន្ធឆ្នាំ២០២៣ និងសេចក្តីសម្រេចក្នុងវេទិការាជរដ្ឋាភិបាល និងផ្នែកឯកជនលើកទី១៩។

(១០) បន្តពង្រឹងកិច្ចសហការជាមួយវិស័យឯកជន ជាពិសេសក្នុងក្របខ័ណ្ឌនៃកិច្ចសហការជាមួយវិស័យឯកជន និងសភាពាណិជ្ជកម្មនានា។

(១១) បន្តជំរុញលើការងាររៀបចំ ចរចា និងពង្រីកវិសាលភាពនៃកិច្ចព្រមព្រៀងស្តីពីការលុបបំបាត់ការយកពន្ធត្រួតគ្នា (DTA) ជាមួយបណ្តាប្រទេសនានា។

(១២) បន្តពង្រឹងតម្លាភាព និងគណនេយ្យភាពនៃការបង់ពន្ធរបស់សហគ្រាសក្នុងវិស័យផលិតស្រាបៀរ និងភេសជ្ជៈគ្មានជាតិសុរា ដោយបន្តពង្រឹងអនុវត្តយន្តការបំពាក់កាមេរ៉ាសុវត្ថិភាពនៅតាមរោងចក្រផលិតស្រាបៀរ និងភេសជ្ជៈគ្មានជាតិសុរាឱ្យបានរួចរាល់គ្រប់សហគ្រាស ការចុះត្រួតពិនិត្យឧបករណ៍វាស់ចំណុះ (Flowmeter) ក្នុងខ្សែច្រវាក់ផលិតកម្មដល់ទីតាំងដោយថ្នាក់ដឹកនាំរបស់អគ្គនាយកដ្ឋានពន្ធដារ និងការបន្តពង្រឹងការអនុវត្តការងារនិងវត្តមានរបស់មន្ត្រីប្រចាំការ។

(១៣) រៀបចំលិខិតបទដ្ឋានគតិយុត្ត និងផែនការសកម្មភាពដើម្បីគាំទ្រការអនុវត្តវិធានការនានាពាក់ព័ន្ធនឹងពន្ធដារ ដូចមានកំណត់នៅក្នុងយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ២០២៣-២០២៨ របស់រាជរដ្ឋាភិបាល។

(១៤) បន្តចូលរួមក្នុងក្របខ័ណ្ឌការងារប្រឆាំងនឹងបទល្មើសសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ជាមួយគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មនិងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ (គ.ស.ហ) និងអនុគណៈកម្មការចំពោះកិច្ចអនុវត្តផែនការសកម្មភាពការងាររបស់ក្រុមការងារត្រួតពិនិត្យរួម នៃក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកអំពីកិច្ចសហប្រតិបត្តិការអន្តរជាតិ (អ.អ.ផ)។

(១៥) បន្តផ្សព្វផ្សាយច្បាប់ស្តីពីសារពើពន្ធថ្មីជូនដល់អ្នកជាប់ពន្ធ សាធារណជន ព្រមទាំងក្រុមការងារវិស័យឯកជន និងអង្គការសមាគមនានាតាមគ្រប់រូបភាព ព្រមទាំងបន្តរៀបចំធ្វើបច្ចុប្បន្នភាពលិខិតបទដ្ឋានគតិយុត្តនានា ស្តីពីពន្ធដារឱ្យស្របតាមច្បាប់ស្តីពីសារពើពន្ធថ្មី។

(១៦) បន្តការងារកែទម្រង់ធនធានមនុស្ស ដោយជំរុញនិងខិតខំពង្រឹងការអនុវត្តច្បាប់ វិន័យការងារ និងត្រូវមានភាពទន់ភ្លន់ តែម៉ឺងម៉ាត់ដោយផ្អែកលើទិដ្ឋភាពច្បាប់ក្នុងការផ្តល់សេវាអ្នកជាប់ពន្ធ និងការគ្រប់គ្រងប្រមូលចំណូលពន្ធ។

(១៧) បន្តពង្រឹងការផ្តល់សេវាពិគ្រោះយោបល់និងការផ្សព្វផ្សាយច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារតាមគ្រប់រូបភាព ជាពិសេសការផ្តល់សេវាពិគ្រោះយោបល់តាមរយៈទូរស័ព្ទ (Call Center-1277) និងការរៀបចំកម្មវិធី "ពន្ធដារកម្ពុជា" (GDT Facebook Live) ដើម្បីពន្យល់និងដោះស្រាយការលំបាក និងចម្ងល់នានារបស់ប្រជាពលរដ្ឋ។

(១៨) បន្តពង្រឹងការងារចុះបញ្ជីពន្ធដារនិងធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាសនិងបន្តសហការ ចូលរួមកែលម្អ និងជំរុញការងារចុះបញ្ជីសហគ្រាសតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន (CamDX) ឱ្យកាន់តែមានប្រសិទ្ធភាព និងមានភាពគ្រប់ជ្រុងជ្រោយ។

(១៩) បន្តពង្រឹងប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាពរបស់ក្រុមការងារអ្នកនាំពាក្យនិងប្រតិកម្មរហ័សនៃអគ្គនាយកដ្ឋានពន្ធដារ និងការចូលរួមយ៉ាងសកម្មជាមួយក្រុមការងារតាមដានសាធារណមតិ និងប្រតិកម្មរហ័សរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីតាមដានបញ្ហាសាធារណមតិ និងផ្សព្វផ្សាយឱ្យសាធារណជនបានជ្រួតជ្រាបកាន់តែច្បាស់ពីការខិតខំប្រឹងប្រែង និងសមិទ្ធផលយ៉ាងសន្ធឹកសន្ធាប់ដែលរាជរដ្ឋាភិបាលបានសម្រេចជូនជាតិមាតុភូមិ។ [៦]

លទ្ធផលការងារប្រមូលពន្ធសរុបរយៈពេល ៩ខែ ឆ្នាំ២០២៥ ចំណូលពន្ធ-អាករដែលប្រមូលបានជាក់ស្តែងតាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនទ្បាញរបស់អគ្គនាយកដ្ឋានពន្ធដារមាន ១១.០៣០,៣៣ ប៊ីលានរៀល (ប្រមាណជា ២.៧៥០,៧១ លានដុល្លារ) ស្មើនឹង ៦៧,៧៥% នៃផែនការដែលបានកំណត់ក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥។ [៧]

- **គោលនយោបាយរូបិយវត្ថុ៖**

សម្រាប់ឆ្នាំ២០២៦ ធនាគារជាតិ នៃ កម្ពុជា បានកំណត់អនុវត្តន៍គោលនយោបាយរូបិយវត្ថុចំនួន៥ ដើម្បីគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការស្តារកំណើនសេដ្ឋកិច្ចជាតិ រួមមាន៖

(១) បន្តគ្រប់គ្រងការផ្គត់ផ្គង់រូបិយវត្ថុឱ្យស្ថិតក្នុងកម្រិតសមស្រប

(២) បន្តរក្សាស្ថិរភាពអត្រាប្តូរប្រាក់ ដើម្បីរួមចំណែករក្សាស្ថិរភាពថ្លៃ និងជំនឿទុកចិត្តរបស់សាធារណជនលើរូបិយវត្ថុជាតិ

(៣) បន្តលើកកម្ពស់ការប្រើប្រាស់ និងចំណេះដឹងពីប្រាក់រៀល

(៤) បន្តពង្រឹងប្រសិទ្ធភាពឧបករណ៍នយោបាយរូបិយវត្ថុដែលមានស្រាប់ និងការអនុវត្តក្របខណ្ឌកូរីដ័រអត្រាការប្រាក់ ព្រមទាំងអភិវឌ្ឍឧបករណ៍នយោបាយរូបិយវត្ថុថ្មីៗ តាមការចាំបាច់ និង

(៥) បន្តលើកកម្ពស់ការយល់ដឹងរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុស្តីពីក្របខណ្ឌនិងឧបករណ៍នយោបាយរូបិយវត្ថុរបស់ធនាគារជាតិ នៃ កម្ពុជា។ [១]


ឯកសារយោង:

(១) https://www.nbc.gov.kh/download_files/publication/annual_rep_kh/Annual_Report_2025_K.pdf

(២) https://www.khmertimeskh.com/501625074/cambodias-economy-projected-to-grow-at-6-3-in-2025/

(៣) https://www.adb.org/news/cambodia-economy-set-grow-tariff-risks-cloud-outlook-adb

(៤) https://www.imf.org/en/-/media/files/publications/reo/apd/2025/october/english/text.pdf

(៥) https://www.worldbank.org/en/news/press-release/2025/12/11/strong-buffers-and-targeted-reforms-can-help-cambodia-withstand-ec pressures-says-world-bank

(៦) https://www.tax.gov.kh/u6rhf7ogbi6/gdtstream/2e8790c9-020b-453f-b743-4b1bad3729a8

(៧) https://www.tax.gov.kh/u6rhf7ogbi6/gdtstream/a95ddc14-bb4e-4a19-ad98-dbfdffa1dca0


**ហត្ថលេខាអភិបាលរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ**

ថ្ងៃអង្គារ ៨រោច ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២៦

ធនាគារ អេស៊ីលីដា ភីអិលស៊ី
ACLEDA BANK PLC.

ជំនួសអោយ ... និងឯកភាព

ហត្ថលេខា

**គីម សុធាវី**

**ប្រធានក្រុមប្រឹក្សាភិបាល**

ការិយាល័យកណ្ដាល ៖ អគារលេខ៦១ មហាវិថីព្រះមុនីវង្ស
សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០២៣ ៩៩៨ ៧៧៧
acledabank@acledabank.com.kh | www.acledabank.com.kh
ប្រអប់សំបុត្រលេខ ៖ ១១៤៩ | SWIFT Code ៖ ACLBKHPP

ការិយាល័យទំនាក់ទំនងអតិថិជន (បម្រើ ២៤ម៉ោង)
ទូរស័ព្ទ ៖ ០២៣ ៩៩៤ ៤៤៤, ០១៥ ៩៩៩ ២៣៣
inquiry@acledabank.com.kh